ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ៣ ត្រីមាសទី៣ ឆ្នាំ២០១៩

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ក ស វ




ECOSOCC

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
www.ecosocc.gov.kh
info@ecosocc.kh
(855) 012 915 577 (855) 012 912 009

## គតិបណ្ឌិត

" ប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ក៏ជាវិញ្ញាសាដែលត្រូវថែទាំ ដុសខាត់ ការពារ និងអភិវឌ្ឍវាជារៀងរហូត។ "

កម្ពុជាឆ្នាំ២០០០ - សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ក្រុមការងារព្រឹត្តិបត្រ
នាយកគ្រប់គ្រង:
- យឹម ណុលសន
និពន្ធនាយក:
- អ៊ុំ ថុង
និពន្ធនាយករង:
- អ៊ុន វ៉ាល់ឡឺរ៉ូ
- ប៉ិច សុខា
ការិយាល័យនិពន្ធ:
- នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត
- លី គឹមសុខ
- ឆយ អូន
- ទីប្រឹក្សា
- សមាជិក
- សមាជិកា នៃ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.)
អ្នកចាត់ចែងផលិត:
- អ៊ុន វ៉ាល់ឡឺរ៉ូ
- រ័ត្ន សណ្ដាប់
អ្នកចែកផ្សាយ:
- អេង រត្នមុនី
- សំ សំណាង
- សេក វុទ្ធី
ការីកុំព្យូទ័រ:
- សយ វាស្នា
- យឹម ច័ន្ទតារា

# មាតិកា

ទំព័រ

I- វិចារណកថា " របបប្រល័យពូជសាសន៍កម្ពុជាប្រជាធិបតេយ្យ និង ថ្ងៃ៧ មករា ជាថ្ងៃបើកទំព័រប្រវត្តិសាស្រ្តថ្មីរបស់កម្ពុជា " ១-២

II- បទអត្ថាធិប្បាយ " ទស្សនាទាននៃដំណើរការរួមគ្នារបស់ស្ថានីយ-វារីអគ្គិសនី និងស្ថានីយអគ្គិសនីពន្លឺព្រះអាទិត្យ " ៣-៥

III- ការពិនិត្យផ្ដល់យោបល់លើសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្ត
- ១- គោលនយោបាយជាតិស្ដីពី ភាសាខ្មែរ ៦-៧
- ២- ច្បាប់ស្ដីពីកិច្ចការពារអ្នកប្រើប្រាស់ ៨-៩
- ៣- ការធ្វើបច្ចុប្បន្នកម្មគោលការណ៍ណែនាំស្ដីពីនីតិវិធី និងវិធាន នៃការតាក់តែងសេចក្ដីព្រាងច្បាប់ និង លិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ១០-១២

IV- ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំឆមាសទី១ ឆ្នាំ២០១៩ ១៣-២១

V- កម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ២២-៣០

VI- សកម្មភាពផ្សេងៗរបស់ថ្នាក់ដឹកនាំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ៣១-៣៤

VII- នាទីវប្បធម៌
- ពន្យល់ពាក្យ (ហេតុ) ៣៥-៣៦
- កម្លាំងអរិយធម៌បិតនៅលើអ្វី? ៣៧-៣៨

VIII- នាទីកំណាព្យ
- ស្មៅចិញ្ចៀន (បទពាក្យ៩) ៣៩
- ច្បាប់ពាក្យចាស់ (បទព្រហ្មគីតិ) ៣៩
- ភូមិខ្ញុំ (បទពាក្យ៧) ៣៩

IX- នាទីកំសាន្ត
- វិះភ្លាត់! ៤០
- ចុមបាត់ញើសអស់! ៤១

X- ពីនេះពីនោះ
- ដុល្លារូបនីយកម្មនៅកម្ពុជា ៤២-៤៦

# របបប្រល័យពូជសាសន៍កម្ពុជាប្រជាធិបតេយ្យ និងថ្ងៃ៧ មករា ជាថ្ងៃបើកទំព័រប្រវត្តិសាស្ត្រថ្មីរបស់កម្ពុជា

*ដោយ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា*

ថ្មីៗនេះ ចំពោះការស្លាប់លោក **នួន ជា** ក៏ដូចជាមេដឹកនាំខ្មែរក្រហមដទៃទៀត ដែលជាមេដឹកនាំជាន់ខ្ពស់ក្នុងរបបខ្មែរក្រហម ហើយត្រូវបានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ឬសាលាក្តីខ្មែរក្រហម បានផ្តន្ទាទោសឱ្យជាប់គុកអស់មួយជីវិត ក្នុងសំណុំរឿងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋ-កម្មប្រល័យពូជសាសន៍ និងការបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលបានប្រព្រឹត្តនៅលើទឹកដីកម្ពុជា ចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩មកនេះ គឺជាកញ្ចក់ឆ្លុះបញ្ចាំងប្រវត្តិសាស្ត្រខ្មែរពីការរស់រានមានជីវិតឡើងវិញរបស់ប្រជាជនកម្ពុជានាថ្ងៃ៧ មករា ឆ្នាំ១៩៧៩។

ថ្ងៃ៧ មករា គឺជាកញ្ចក់ឆ្លុះបញ្ចាំងប្រវត្តិសាស្ត្រខ្មែរ នៃកាលបរិច្ឆេទរំដោះប្រជាជនកម្ពុជាឱ្យរួចផុតពីរបបប្រល័យពូជសាសន៍ ដែលបង្កឡើងដោយពួកពេជ្ឈឃាតប៉ុលពត គឺត្រឹមរយៈពេលជាងបីឆ្នាំប៉ុណ្ណោះ អាយុជីវិតប្រជាជនកម្ពុជាជាង២លាននាក់ត្រូវរបបប៉ុលពតកាប់សម្លាប់ និងសមិទ្ធផលជាតិត្រូវបានកម្ទេចចោលយ៉ាងព្រៃផ្សៃបំផុត។ បើហេតុនេះ តើគេអាចកសាងអនាគតដ៏ល្អប្រសើររបស់ប្រទេសមួយបានទេ បើគេពុំរំលឹកដល់មេរៀនប្រវត្តិសាស្ត្រនោះ? គេតែងនិយាយថា « អ្នកណាដែលបំភ្លេចមេរៀនប្រវត្តិសាស្ត្រ នឹងត្រូវផ្តន្ទាទោសឱ្យរស់នៅក្នុងប្រវត្តិសាស្ត្រដដែលឡើងវិញ »។

ជាទូទៅ ប្រទេសនីមួយៗ ប្រជាជាតិនីមួយៗ អ្នកប្រវត្តិសាស្ត្រគេតែងកត់ត្រានូវភាពអាប់ឱន និងភាពរុងរឿងនៃប្រវត្តិសាស្ត្ររាប់ពាន់ឆ្នាំរបស់គេ ដើម្បីចៀសវាងមិនឱ្យការរស់នៅក្នុងភាពឈឺចាប់និងលំបាកវេទនាមានជីវិតរស់ឡើងវិញ។ ភស្តុតាងប្រវត្តិសាស្ត្រកម្ពុជាបានប្រាប់ថា កាលពីក្នុងយុគសម័យអន្ធការរបស់កម្ពុជា ហើយដែលប្រជាជនកម្ពុជានៅតែដក់ជាប់ក្នុងសន្តានចិត្ត និងដក់ជាប់ក្នុងអារម្មណ៍របស់យើងគ្រប់ៗគ្នានោះ គឺរបបវាលពិឃាដតដែលសង្គមជាតិទាំងមូលត្រូវក្រឡាប់ចាក់លង់លិចយ៉ាងជ្រៅក្នុងអន្លង់ជ្រោះមហន្តរាយប្រល័យពូជសាសន៍ ដែលជាសម័យកាលដ៏សោកសៅ និងខ្មៅងងឹតបំផុតក្នុងប្រវត្តិសាស្ត្រកម្ពុជា។

អរិយធម៌សង្គមកម្ពុជាដែលធ្លាប់ជាសង្គមមួយមានអរិយធម៌យ៉ាងឧត្តុង្គឧត្តម ត្រូវបានបំផ្លាញរហូតដល់ឫសគល់ដោយសាររបបពេជ្ឈឃាត។ ស្ថាប័ននិងហេដ្ឋារចនាសម្ព័ន្ធរដ្ឋដែលជាខឿនសេដ្ឋកិច្ច ពាណិជ្ជកម្ម សង្គមកិច្ច វប្បធម៌ វត្តអារាម។ល។ ត្រូវរលាយសូន្យ។ ស្រុក ឃុំ ភូមិទូទាំងប្រទេសត្រូវប្រែក្លាយជាជំរំឃុំឃាំង។ ប្រជាជនរាប់លាននាក់ត្រូវបង្ខំឱ្យធ្វើពលកម្មដ៏ធ្ងន់ធ្ងរ ទាំងថ្ងៃ ទាំងយប់ អត់អាហារ ខ្វះសម្លៀកបំពាក់ ខ្វះថ្នាំសង្កូវ ព្រាត់ប្រាសពីក្រុមគ្រួសារបងប្អូន កូនចៅរស់ដូចសត្វធាតុ គ្រៀមក្រំគិតភ័យគ្មានទីសង្ឃឹម។ ទឹកដីទាំងមូលជោគជាំទៅដោយឈាមនិងទឹកភ្នែក ក្រាលទៅដោយឆ្អឹងនិងគំនរផេះ។ យើងយល់ថា ទំហំនិងទម្ងន់នៃបទឧក្រិដ្ឋនេះធំធេងណាស់ ដែលពិភពលោកទាំងមូលគេទទួលមិនបាន។

ចំពោះមុខសភាពការណ៍ដ៏រន្ធត់បែបនេះ ប្រជាជនកម្ពុជាគ្រប់រូបនាពេលនោះ បាននឹកបន់ស្រន់អំពាវនាវ ដង្ហោយហៅ សុំអ្នកមានបុណ្យ អ្នកមានមហិទ្ធិឫទ្ធិ ពូកែសក្តិសិទ្ធិណាមួយរូបអាចមកជួយរំដោះអាយុជីវិតពួកគេ ឱ្យបានរួចផុតពីក្រញាំបីសាចនេះ។

ស្ថិតក្នុងបរិការណ៍នេះ ចំពោះការទទួលបាននូវជ័យជម្នះ នាថ្ងៃ៧ មករា ១៩៧៩ សម្រាប់កម្ពុជាគឺជាការបើកទំព័រប្រវត្តិសាស្ត្រថ្មីនៃការរស់ឡើងវិញទាំងជីវិត ទាំងគ្រប់វិស័យ ដែលបច្ចុប្បន្ននេះកម្ពុជាកំពុងទទួលបាននូវក្លិនពិដោរដ៏ឈ្ងុយឈ្ងប់ មានឈ្មោះបោះសំឡេងគ្រប់ទិសទីទាំងនៅក្នុងតំបន់ ទាំងលើឆាកអន្តរជាតិ។

ស្ថិតក្នុងឱកាសនេះ យើងសូមឧទ្ទិសថ្ងៃ៧ មករា ជាថ្ងៃដែលយើងមិនត្រូវបំភ្លេចនូវប្រវត្តិសាស្ត្រដ៏ឈឺចាប់ ជាថ្ងៃដែលយើងត្រូវរំលឹកនូវការប្រល័យពូជសាសន៍ ជាថ្ងៃដែលខ្មែរគ្រប់រូបត្រូវមានបេះដូងទទួលស្គាល់នូវគុណធម៌ មិនត្រូវបំភ្លេចអ្នកដែលមានគុណលើខ្លួន ពេលដែលខ្លួននិងឪពុកម្តាយខ្លួន បានរួចផុតពីគ្រោះមរណៈ ហើយបច្ចុប្បន្ន យើងទាំងអស់គ្នាកំពុងរស់នៅក្នុងប្រទេសមួយ និងសង្គមមួយដែលកំពុងរីកចម្រើនគ្រប់វិស័យ ជាពិសេសវិស័យសេដ្ឋកិច្ច យ៉ាងលឿនស្លេវទៅមុខជានិច្ច គ្មានជនណាឬបរទេសណាទប់បានឡើយ ក្នុងប្រទេសមួយនិងសង្គមមួយដែលស្ថិតក្នុងទីសុខសាន្ត។

ដោយសារអ្នកណា? គឺដោយសារសម្តេចទាំង៣ ជាពិសេស **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។

សូមបងប្អូនកូនក្មួយកុំភ្លេចឱ្យសោះ ទោះបីក្នុងកាលៈទេសៈណាក៏ដោយ។

"បើបានទឹកពិសារស់រានមានជីវិតហើយ សូមកុំភ្លេចប្រភពទឹកនោះឱ្យសោះ"

# ទស្សនាទាន
# ដំណើរការរួមគ្នារបស់ស្ថានីយវារីអគ្គិសនី និង ស្ថានីយអគ្គិសនីពន្លឺព្រះអាទិត្យ

*ដោយ បណ្ឌិត អ៊ុច ថេងសេង*

អត្ថបទនេះមានគោលបំណងបង្ហាញពីលទ្ធភាពបញ្ចុះថ្លៃអគ្គិសនីដោយដំណើរការស្ថានីយវារីអគ្គិសនី និងស្ថានីយអគ្គិសនីពន្លឺព្រះអាទិត្យរួមគ្នា។

ប្រជាជនលើពិភពលោកទាំងមូលទទួលស្គាល់ថា ក្នុងឆ្នាំ២០១៩ នេះ កម្តៅក្នុងរដូវប្រាំងក្តៅជាងកម្តៅពីឆ្នាំមុនៗ និងក្នុងរដូវភ្លៀង បរិមាណទឹកភ្លៀងមានច្រើនជាងមុននៅកន្លែងធ្លាក់ទឹកភ្លៀង ឧទាហរណ៍ ការជន់លិចតំបន់ខ្លះនៃទីក្រុងព្រះសីហនុដែលមិនធ្លាប់មានពីមុនមក។ បាតុភូតធ្លាក់បរិមាណទឹកភ្លៀងច្រើនជាងមុន ឬខ្យល់ព្យុះមានកម្លាំងខ្លាំងជាងមុន បណ្តាលមកពីបរិមាណចំហាយទឹករសាត់ពីផ្ទៃផែនដីទៅក្នុងអាកាសនៅក្នុងរដូវប្រាំងមានចំនួនច្រើនជាងឆ្នាំមុនៗ លុះដល់ពេលបរិមាណចំហាយទឹកនេះរសាត់ក្នុងអាកាសបង្កទៅជាទឹកភ្លៀង ក៏បង្កើតទៅជាភ្លៀងដែលមានបរិមាណទឹកច្រើន។ ភស្តុតាងនៃកំណើនកម្តៅក្នុងឆ្នាំ២០១៩ នៅទីក្រុងឆឺណៃ (Chennai) នៃរដ្ឋតាមិលណាឌូ ប្រទេសឥណ្ឌា ដែលមានប្រជាជនប្រើប្រាស់ទឹកក្រោមដីសម្រាប់ការផ្គត់ផ្គង់ទឹក។ នៅពេលទឹកស្រកចុះរហូតស្ទើរមិនមានទឹកក្នុងអណ្តូង រដ្ឋត្រូវដឹកទឹកតាមរថភ្លើងមកផ្គត់ផ្គង់ប្រជាជនវិញ ។

ក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុឆ្នាំ២០១៥ ហៅកាត់ COP 21 ប្រទេសជាហត្ថលេខីបានព្រមព្រៀងកាត់បន្ថយកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ឬឧស្ម័នកាបោនិកទៅក្នុងអាកាសដើម្បីកាត់បន្ថយកំណើនកម្តៅពិភពលោកឲ្យនៅក្រោម ២អង្សា ។ ដំណើរការស្ថានីយវារីអគ្គិសនី និងស្ថានីយអគ្គិសនីពន្លឺព្រះអាទិត្យនៅកម្ពុជា មិនត្រឹមតែរួមចំណែកកាត់បន្ថយកំណើនកម្តៅពិភពលោកប៉ុណ្ណោះទេ ថែមទាំងកាត់បន្ថយជាតិពុលទៅក្នុងខ្យល់ដកដង្ហើមនៅក្នុងប្រទេសកម្ពុជា ដែលបង្កដោយការដុតប្រេង ឬធ្យូងថ្មដើម្បីផលិតអគ្គិសនី។

នៅក្នុងវិស័យអគ្គិសនី ការប្រើប្រាស់អគ្គិសនីប្រចាំថ្ងៃត្រូវបានតំណាងដោយក្រាហ្វិកដូចខាងក្រោម៖



Figure 7: Daily Peak Load Curve from 2010 to 2015 in National Grid

ក្រាហ្វិកនេះត្រូវបានពន្យល់ដូចតទៅ៖

-ពីម៉ោង១យប់ដល់ម៉ោង៦ភ្លឺ ការប្រើប្រាស់អគ្គិសនីទាប ព្រោះមនុស្សសំរាក(ដេក)

-ពីម៉ោង៧ព្រឹកដល់ម៉ោង១១ព្រឹក ការប្រើប្រាស់អគ្គិសនីកើនឡើង ដោយសាររោងចក្រ មន្ទីរក្រសួង មន្ទីរពេទ្យ និងហាងលក់ដូរដំណើរការ

-ពីម៉ោង១២ថ្ងៃត្រង់ដល់ម៉ោង១ល្ងាច ការប្រើប្រាស់អគ្គិសនីចុះ នៅម៉ោងសំរាកបាយថ្ងៃត្រង់

-ពីម៉ោង២ល្ងាចដល់ម៉ោង៥ល្ងាច ការប្រើប្រាស់អគ្គិសនីកើនឡើងវិញ ម៉ោងធ្វើការល្ងាច

-ពីម៉ោង៥ល្ងាចដល់ម៉ោង៦ល្ងាច ម៉ោងចេញពីធ្វើការ

-ពីម៉ោង៦ល្ងាចដល់ម៉ោង១០យប់ ការប្រើប្រាស់អគ្គិសនីកើនឡើងដោយសារភ្លើងបំភ្លឺផ្លូវ មនុស្សចូលផ្ទះវិញ ប្រើអគ្គិសនីបំភ្លឺផ្ទះ រៀបចំចំអិនអាហារ បើកទូរទស្សន៍...

ចំណុចគួរកត់សម្គាល់នៅលើក្រាហ្វិកប្រើប្រាស់អគ្គិសនីឆ្នាំ២០១៥ មានដូចខាងក្រោមៈ

-ការប្រើប្រាស់អគ្គិសនីទាបបំផុត ឬអប្បបរមា ហៅថា Base Load ស្មើនឹង ៥០០ ម៉េហ្គាវ៉ាត់ មានរយៈពេល ៥ ទៅ ៦ ម៉ោង

-ការប្រើប្រាស់អគ្គិសនីមធ្យម ស្មើនឹង ៧០០ ម៉េហ្គាវ៉ាត់ មានរយៈពេល ១៥ ម៉ោង

-ការប្រើប្រាស់អគ្គិសនីខ្ពស់បំផុត ឬអតិបរមា ហៅថា Peak Load ស្មើនឹង ៩៤០ ម៉េហ្គាវ៉ាត់ មានរយៈពេល ២ ទៅ ៣ ម៉ោង

ស្ថានីយអគ្គិសនីគ្រប់ប្រភេទ រួមទាំងស្ថានីយដុតប្រេងនិងធ្យូងថ្មត្រូវដំណើរការរួមគ្នា ដើម្បីផ្គត់ផ្គង់សេចក្តីត្រូវការថាមពលនេះ។ ការសាងសង់ស្ថានីយអគ្គិសនីថ្មីដើម្បីផ្គត់ផ្គង់តម្រូវការអគ្គិសនី មានចំនួនច្រើនរហូតដល់រាប់ពាន់លានដុល្លារ ដែលមិនអាចប្រើប្រាស់ថវិកាជាតិទាំងអស់បាន ទើបមានបទពិសោធន៍អនុញ្ញាតឲ្យឯកជនសាងសង់ស្ថានីយអគ្គិសនី Private Power Participation ផលិតនិងលក់អគ្គិសនីមកឲ្យក្រុមហ៊ុនរដ្ឋសំរាប់ចែកចាយ។

ជាទូទៅ ក្រុមហ៊ុនអគ្គិសនីឯកជន Independent Power Producer ដែលផលិតអគ្គិសនីសម្រាប់លក់មកឲ្យក្រុមហ៊ុនអគ្គិសនីរដ្ឋសម្រាប់ចែកចាយមិនមានធនធាន Capital គ្រប់គ្រាន់សំរាប់ការវិនិយោគសាងសង់នេះទេ ហើយត្រូវខ្ចីធនាគារមកបង្គ្រប់ធនធានដែលខ្លួនមាន ដែលតម្រូវឲ្យក្រុមហ៊ុនអគ្គិសនីឯកជនទាំងនោះបង់ការប្រាក់ និងប្រាក់រំលោះដើមទៅធនាគារ។

ដើម្បីមានចំណូលគ្រប់គ្រាន់សម្រាប់បង់ការប្រាក់ និងប្រាក់រំលោះដើមទៅធនាគារ ក្រុមហ៊ុនអគ្គិសនីឯកជនត្រូវដំណើរការស្ថានីយអគ្គិសនីរបស់ខ្លួនក្នុងរយៈពេល ២៤ម៉ោង ដើម្បីរកចំណូលឲ្យបានគ្រប់ម៉ោង។ ក្នុងករណីត្រូវដំណើរការផ្គត់ផ្គង់ការប្រើប្រាស់អគ្គិសនីខ្ពស់បំផុតរយៈពេល ២ ទៅ ៣ ម៉ោង ក្រុមហ៊ុនអគ្គិសនីឯកជនអាចមានជំរើសពីរៈ

-លក់អគ្គិសនីនៅម៉ោង Peak ដែលអាចមានរយៈពេល ២ ទៅ ៧ ម៉ោង ក្នុងតម្លៃថ្លៃ ឬ

-គិតថ្លៃអគ្គិសនីនៅម៉ោងដែលស្ថានីយអគ្គិសនីរបស់ខ្លួនមិនដំណើរការ ដោយប្រើប្រាស់រូបមន្ត

Price = Fixed Cost + Variable Cost + Profits

| | |
|---|---|
| Price | ថ្លៃលក់អគ្គិសនីក្នុងមួយគីឡូវ៉ាត់ម៉ោង |
| Fixed Cost | ថ្លៃលក់ថេរ ឬហៅថា Capacity Charges ដែលអាចជាប្រាក់ត្រូវបង់ទៅធនាគារ និងប្រាក់ខែអ្នកដំណើរការស្ថានីយ |
| Variable Cost | ប្រាក់ចំណាយផ្សេងៗទាក់ទងនឹងដំណើរការផលិតអគ្គិសនី ដូចជាថ្លៃប្រេង... |
| Profit | ប្រាក់ចំណេញ |

ដើម្បីកាត់បន្ថយថ្លៃអគ្គិសនី ការកាត់បន្ថយថ្លៃលក់ថេរ ឬហៅថា Capacity Charges ជាវិធីមួយដែលអាចអនុវត្តបានដោយដំណើរការរួមគ្នារវាងស្ថានីយវារីអគ្គិសនី និងស្ថានីយអគ្គិសនីពន្លឺព្រះអាទិត្យ។ ដំណើរការស្ថានីយអគ្គិសនីពន្លឺព្រះអាទិត្យ ឬសូឡា ដែលដំណើរការដោយមិនមានអាគុយសម្រាប់ស្តុកថាមពលសម្រាប់ប្រើពេលគ្មានពន្លឺថ្ងៃ អាចតំណាងដោយក្រាហ្វិកដូចខាងក្រោម៖






ការប្រៀបធៀបក្រាហ្វិកខាងលើបង្ហាញថា៖

-បើសិនជា អានុភាពស្ថានិយវារីអគ្គិសនីស្មើ ១០០០ មេហ្គាវ៉ាត់ និងអានុភាពស្ថានិយសូឡាស្មើនឹង ១០០០ មេហ្គាវ៉ាត់ដែរ អានុភាពរួមនៃដំណើរការស្ថានីយទាំងពីរមិនស្មើ ២០០០ មេហ្គាវ៉ាត់ទេ ព្រោះនៅរដូវក្តៅ ស្ថានីយវារីអគ្គិសនីផលិតអគ្គិសនីបានតិច និងនៅរដូវភ្លៀង ស្ថានីយសូឡាផលិតអគ្គិសនីបានតិច និងមិនអាចផលិតអគ្គិសនីនៅពេលយប់។ ការប៉ាន់ស្មានថា ដំណើរការរួមនៃស្ថានីយទាំងពីរស្មើ ២០០០ មេហ្គាវ៉ាត់ អាចនាំឲ្យមានការខ្វះថាមពលអគ្គិសនីសម្រាប់ចែកចាយ។

-ក្រុមហ៊ុនវិនិយោគដំណើរការស្ថានីយវារីអគ្គិសនីមិនអាចទារថ្លៃមិនដំណើរការស្ថានីយ Fixed cost នៅរដូវប្រាំង ហើយក្រុមហ៊ុនស្ថានីយសូឡាក៏មិនអាចទារថ្លៃមិនដំណើរការស្ថានីយ Fixed cost នៅរដូវភ្លៀងឬពេលយប់បានឡើយ ។

-ដំណើរការរួមគ្នានៃស្ថានីយទាំងពីរអាចកាត់បន្ថយថ្លៃមិនដំណើរការស្ថានីយ Fixed cost កាត់បន្ថយថ្លៃដើមអគ្គិសនី កាត់បន្ថយការបំភាយឧស្ម័នពុលទៅក្នុងខ្យល់ដកដង្ហើម៕

## III- ការពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត

### ១- សេចក្តីព្រាងគោលនយោបាយជាតិស្តីពីភាសាខ្មែរ



បញ្ញត្តិនៃ ”ភាសាខ្មែរ” ជាបញ្ញត្តិគោលមួយដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ក្នុងជំពូកទី១ មាត្រាទី៥ ដែលចែងថា ” ភាសានិងអក្សរដែលប្រើជាផ្លូវការ គឺភាសានិងអក្សរខ្មែរ ”។ ក្នុងន័យនេះ ភាសានិងអក្សរខ្មែរត្រូវបានកំណត់ច្បាស់សម្រាប់ការប្រើប្រាស់និងការប្រាស្រ័យទាក់ទងគ្នាលើគ្រប់វិស័យស្របតាមតម្រូវការ ដើម្បីធ្វើឲ្យមានសុដុមរមនាក្នុងការអភិវឌ្ឍសង្គមជាតិ។ ឯក្នុងកថាខណ្ឌទី២នៃមាត្រាទី៦៩ក្នុងរដ្ឋធម្មនុញ្ញ ក៏បានចែងថា”រដ្ឋមានកាតព្វកិច្ចការពារនិងពង្រីកភាសាខ្មែរឲ្យសមស្របនឹងសេចក្តីត្រូវការ”។ អនុលោមតាមបញ្ញត្តិនេះ ច្បាប់ស្តីពីអប់រំឆ្នាំ២០០៧ នៅក្នុងជំពូកទី៥ មាត្រាទី២៤ បានចែងថា”ភាសាខ្មែរជាភាសាយាន និងជាមុខវិជ្ជាមួយនៃកម្មវិធីសិក្សាគោលនៅសាលារៀនចំណេះទូទៅសាធារណៈ។ ចំពោះសាលារៀនចំណេះទូទៅឯកជន ត្រូវមានកម្មវិធីសិក្សាភាសាខ្មែរជាមុខវិជ្ជាគោលមួយនៃកម្មវិធីសិក្សារបស់ខ្លួន”។

ក្នុងដំណាក់កាលក្រោយប្រទេសត្រូវបានរំដោះឆ្នាំ១៩៧៩ រដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងផ្តល់ឱកាសតាមគ្រប់រូបភាពដល់ប្រជាជនកម្ពុជាគ្រប់រូប ដើម្បីទទួលបានការអប់រំទាំងអស់គ្នា ដោយបានបើកយុទ្ធនាការនៅទូទាំងប្រទេស ដើម្បីរំដោះគ្រោះមិនចេះអក្សរនិងគ្រោះភ្លេចអក្សរ តាមពាក្យស្លោក “អ្នកចេះបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះ” (ទសវត្សឆ្នាំ១៩៨០) និងរៀនហើយរៀនទៀត រៀនមិនចេះចប់(ទសវត្សឆ្នាំ១៩៩០)។

ទន្ទឹមនឹងការវិវត្តនៃសេដ្ឋកិច្ចសង្គមយ៉ាងឆាប់រហ័ស ក្នុងរយៈពេលកន្លងមកនេះ ការប្រើភាសាខ្មែរមិនទាន់មានការឯកភាពគ្នានៅឡើយ ដូច្នេះហើយបានជាប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានផ្តល់អនុសាសន៍ក្នុងពិធីបិទសន្និបាតបូកសរុបការងារនៃក្រសួងអប់រំ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០ ថា “ត្រូវត្រួតពិនិត្យផ្ទៀងផ្ទាត់ឲ្យបានហ្មត់ចត់លើអត្ថបទកិច្ចការស្រាវជ្រាវ កាសែត ទស្សនាវដ្តី គេហទំព័រ ស្លាកសញ្ញានានានៅតាមទីសាធារណៈ ឲ្យរក្សាបាននូវទម្រង់និងក្បួនខ្នាតអក្សរសាស្ត្រ និងភាសាវិទ្យាខ្មែរ ដូចបានរៀបចំនៅក្នុងវចនានុក្រមខ្មែរសម្តេចព្រះសង្ឃរាជ **ជួន ណាត**”។

ដើម្បីដោះស្រាយបញ្ហាប្រឈមមួយចំនួន ព្រមទាំងដើម្បីឆ្លើយតបទៅនឹង ចក្ខុវិស័យនៃភាសាខ្មែរដែលសំដៅដល់ភាសានិយាយ ភាសាសរសេរ និងអក្សរខ្មែរ ក្រុមប្រឹក្សាជាតិភាសាខ្មែរនៃរាជបណ្ឌិត្យសភាកម្ពុជាបានកសាងគោលនយោបាយជាតិស្តីពីភាសាខ្មែរសំដៅតម្រង់ទិសក្នុងការប្រើប្រាស់ ការអភិរក្ស និងការអភិវឌ្ឍភាសាខ្មែរ រួមទាំងអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងឯកភាពជាតិផងដែរ។ ដើម្បីសម្រេចនូវចក្ខុវិស័យ គោល-



បំណង និងគោលដៅដែលបានលើកឡើង យុទ្ធសាស្ត្ររបស់គោលយោបាលត្រូវមានការបង្កើតយន្តការ និងកំណត់គោលការណ៍អភិវឌ្ឍនិងអភិរក្សភាសាខ្មែរ បង្កើនការប្រើភាសាខ្មែរជាភាសាយាន ជំរុញការប្រើពាក្យនិងបច្ចេកសព្ទជាភាសាខ្មែរ ព្រមទាំងពាក្យនិងបច្ចេកសព្ទកម្ចីឲ្យស្របតាមគោលការណ៍ភាសាជាតិ ជំរុញការប្រើភាសាខ្មែរឲ្យបានទូលំទូលាយនិងត្រឹមត្រូវ កំណត់និងត្រួតពិនិត្យឲ្យមានឯកភាពក្នុងការប្រើភាសាខ្មែរ ជំរុញនិងលើកកម្ពស់ការស្រាវជ្រាវ ប្រមូល ចងក្រង ថែរក្សា និងការផ្សព្វផ្សាយឯកសារទាក់ទងនឹងភាសាខ្មែរ។ ជារួមគោលនយោបាយនេះ ទាមទារឲ្យមានការខិតខំប្រឹងប្រែងរួមគ្នាតាមគ្រប់មធ្យោបាយពីគ្រប់ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីឲ្យមានសង្គតិភាពនិងឯកភាពជាតិទាំងមូល។

សេចក្តីព្រាងគោលនយោបាយជាតិស្តីពីភាសាខ្មែរនេះ ត្រូវបានដាក់ឆ្លងកិច្ចប្រជុំជំនាញបច្ចេកទេស នៅទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩ ដឹកនាំដោយសហប្រធាន ឯកឧត្តម **ឆយ អូន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និង ឯកឧត្តម **ស៊ា ម៉ៅ** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ដោយមានឯកឧត្តម **ហ៊ាន សុខុម** ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ តំណាងស្ថាប័នសាមីជាអ្នកការពារសេចក្តីព្រាង។ កិច្ចប្រជុំបានយកចិត្តទុកដាក់ពិភាក្សាលើខ្លឹមសារសេចក្តីព្រាងទាំងមូល ដែលស្ថាប័នសាមីបានរៀបចំឡើង ដើម្បីឲ្យគោលនយោបាយនេះទទួលបាននូវលទ្ធផលជាផ្លែផ្កាពេលដាក់ឲ្យអនុវត្ត តាមរយៈផែនការសកម្មភាពជាក់លាក់នានានៅពេលខាងមុខ៕

*ក.ស.វ. - ក្រុម ៣*

## ២- សេចក្តីព្រាងច្បាប់ស្តីពី

# កិច្ចការពារអ្នកប្រើប្រាស់

សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ត្រូវបានរៀបចំដោយក្រសួងពាណិជ្ជកម្ម និងបានបញ្ជូនមកទីស្តីការគណរដ្ឋមន្ត្រីនៅថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១៧ និងបានឆ្លងកិច្ចប្រជុំជំនាញបច្ចេកទេស នៅទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧ ដឹកនាំដោយសហប្រធាន ឯកឧត្តម **អ៊ុច ចាន់សេង** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងឯកឧត្តម **ស៊ា ម៉ៅ** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ដោយមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម **ម៉ៅ ថូរ៉ា** រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម តំណាងស្ថាប័នសាមី ជាអ្នកការពារសេចក្តីព្រាង និងបានឆ្លងប្រជុំអន្តរក្រសួងដែលបានពិនិត្យ និងកែសម្រួលសេចក្តីព្រាងច្បាប់នេះដល់ជំពូកទី៦។ ជំពូកទី៧ ជំពូកទី៨ ជំពូកទី៩ និងជំពូកទី១០ ដែលមានការពាក់ពន្ធ័នឹងសមត្ថកិច្ចតុលាការ ត្រូវបានក្រសួងយុត្តិធម៌ជួយសម្របសម្រួល។

សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ត្រូវបានអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីអនុម័តនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ សម្រាប់បញ្ជូនទៅរដ្ឋសភា។

មូលដ្ឋានគតិយុត្តនៃការតាក់តែងសេចក្តីព្រាងច្បាប់នេះ

-មាត្រា៦៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហាមឃាត់ និងផ្តន្ទាទោសជាទម្ងន់ដល់ជនណាដែលនាំចូល ផលិត លក់ដូរ គ្រឿងញៀន ទំនិញក្លែងក្លាយ ហួសរយៈពេលប្រើប្រាស់ ដែលប៉ះពាល់ដល់សុខភាព អាយុជីវិតរបស់អ្នកប្រើ ។

-កាតព្វកិច្ចជាសមាជិក WTO និង ASEAN

ខ្លឹមសារគោលក្រោយច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ត្រូវបានអនុម័តនិងដាក់ឱ្យប្រើប្រាស់

-បង្កើតគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ ដោយមានអគ្គនាយកដ្ឋានទទួលបន្ទុកកិច្ចការពារអ្នកប្រើប្រាស់ជាសេនាធិការ(មាត្រា៥ នៃជំពូក២ ស្ថាប័នមានសមត្ថកិច្ច)

-បង្កើតសមាគមអ្នកប្រើប្រាស់ដោយត្រូវចុះបញ្ជីនៅក្រសួងមហាផ្ទៃ ស្របតាមច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល (មាត្រា៦ ជំពូក៣)។ សមាគមនេះមានតួនាទីនិងភារកិច្ចផ្តល់ប្រឹក្សាឯករាជ្យជូនអ្នកប្រើប្រាស់និងធ្វើជាតំណាងការពារសិទ្ធិនិងផលប្រយោជន៍អ្នកប្រើប្រាស់ចំពោះមុខគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ឬតុលាការ។

-ការកំណត់បទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់កំណត់ដោយបញ្ញត្តិករមានសមត្ថកិច្ច និងដែលអាចមានការពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ក្នុងករណីចាំបាច់។

ចំពោះទម្រង់ ច្បាប់នេះមាន ៨ជំពូក

| | | |
|---|---|---|
| ជំពូកទី១ | បញ្ញត្តិទូទៅ | មាន ៤មាត្រា |
| ជំពូកទី២ | ស្ថាប័នមានសមត្ថកិច្ច | មាន ១មាត្រា |
| ជំពូកទី៣ | សមាគមអ្នកប្រើប្រាស់ | មាន ៣មាត្រា |
| ជំពូកទី៤ | អំពើមិនសុចរិតក្នុងធុរកិច្ច | មាន ៤មាត្រា |
| ជំពូកទី៥ | ការអនុវត្តមិនសុចរិត | មាន ១០មាត្រា |
| ជំពូកទី៦ | ព័ត៌មានសម្រាប់អ្នកប្រើប្រាស់ | មាន ៥មាត្រា |
| ជំពូកទី៧ | នីតិវិធីប្តឹងនិងស៊ើបអង្កេត | មាន ៤មាត្រា |
| ជំពូកទី៨ | នីតិវិធីនៃការចេញសេចក្តីសម្រេច | មាន ៦មាត្រា |
| ជំពូកទី៩ | ការប្តឹងតវ៉ា | មាន ២មាត្រា |
| ជំពូកទី១០ | ទោសបញ្ញត្តិ | មាន ១០មាត្រា |
| ជំពូកទី១១ | អវសានប្បញ្ញត្តិ | មាន ២មាត្រា |

ដើម្បីការពារផលប្រយោជន៍អ្នកប្រើប្រាស់ ក្រសួងពាណិជ្ជកម្មក៏បានរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីសុវត្ថិភាពម្ហូបអាហារ។ ការអនុវត្តច្បាប់ទាំងពីររួមគ្នាអាចកាត់បន្ថយគ្រោះថ្នាក់បណ្ដាលមកពីចំណីអាហារ Dietary Diseases។ វេជ្ជបណ្ឌិតចំណីអាហារ Nutritionist បានពន្យល់ថា ជនជាតិអាមេរិករងគ្រោះដោយសារការហូបចំណីអាហារហើយក្លាយជាជនជាតិដែលមានមនុស្សធាត់ Obesities ច្រើនជាងគេក្នុងពិភពលោក ហើយជំងឺធាត់នេះក៏អាចបណ្ដាលឱ្យមានជំងឺផ្សេងទៀត ដូចជា ទឹកនោមផ្អែម មហារីក ...។ វេជ្ជបណ្ឌិតចំណីអាហារពន្យល់ថា កំហុសឆ្គងនេះបណ្ដាល មកពីក្នុងរយៈពេល ៤០ឆ្នាំមុន មានការពន្យល់ថា មូលហេតុនាំឱ្យមានជំងឺគាំងបេះដូង និងដាច់សសៃឈាមខួរក្បាលបណ្ដាលមកពីការបរិភោគជាតិសាច់ច្រើន ហើយមានការណែនាំឱ្យបរិភោគជាតិស្ករជំនួស a calorie is a calorie ។ បច្ចុប្បន្ន វេជ្ជបណ្ឌិតចំណីអាហាររកឃើញថា ការបរិភោគជាតិសាច់ច្រើនមិនមែនជាមូលហេតុតែមួយគត់ទេ គឺកំណកជាតិកាល់ស្យូមក្នុងសសៃឈាម Arteries calcification ដែលជាមូលហេតុដែលបណ្ដាលឱ្យមានជំងឺគាំងបេះដូងនិងដាច់សសៃឈាមខួរក្បាល ហើយការបរិភោគជាតិស្ករច្រើនផ្ដល់ផលអាក្រក់ច្រើនជាង។

មេរោគមហារីកបំបែកខ្លួនរីកធំធាត់ដោយសារជាតិស្ករ។ កោសិកាធម្មតារបស់មនុស្សអាចចិញ្ចឹមខ្លួនដោយសារជាតិស្ករ Glucose ផងនិងជាតិខ្លាញ់ Fat ផង។ វេជ្ជបណ្ឌិតចំណីអាហារពន្យល់ថាការបង្អត់ជាតិស្ករក៏ជាវិធីព្យាបាលជំងឺមហារីកមួយដែរ ព្រោះរាងកាយមនុស្សអាចចិញ្ចឹមខ្លួនបានដោយសារជាតិខ្លាញ់ Ketone។ មានពពួកមេរោគផ្សិត និងកមរមាស់ Fungi and yeast infection ដែលចិញ្ចឹមខ្លួនដោយសារជាតិស្ករដែរ។ ជំងឺទឹកនោមផ្អែមប្រភេទទី ២ Type 2 Diabetes កើតឡើងដោយសារការបរិភោគជាតិផ្អែមលើសកម្រិតនិងអាចបណ្ដាលឱ្យងងឹតភ្នែកនិងដំបៅរលួយរហូតត្រូវកាត់ដៃជើង។ វេជ្ជបណ្ឌិតចំណីអាហារ Nutritionist បញ្ជាក់ថា ជំងឺនេះមិនមែនជាជំងឺរ៉ាំរ៉ៃនិងវិវត្តទៅធ្ងន់ធ្ងរ Chronicle progressive ទេ គឺជាជំងឺចំណីអាហារ Dietaries disease ដែលអាចព្យាបាលឱ្យជាបានដោយការតមជាតិផ្អែមហៅថា Ketones និងការបង្អត់អាហារ Intermittent fasting ដើម្បីកាត់បន្ថយភាពរ៉េស៊ីស្តង់នឹងអាំងសូលីន Insulin resistance។

វេជ្ជបណ្ឌិតចំណីអាហារអះអាងថា សហរដ្ឋអាមេរិករងគ្រោះដោយសារជាតិផ្អែមក្នុងចំណីអាហារ ហើយត្រូវចំណាយថវិកា ៣ ដងដើម្បីព្យាបាលច្រើនជាងប្រាក់ចំណេញរបស់ក្រុមហ៊ុនចំណីអាហារមាន Coca cola និង Fast Food ហើយអះអាងថាសហរដ្ឋអាមេរិកបាននាំចេញជំងឺទឹកនោមផ្អែមទៅប្រទេសផ្សេងទៀតក្នុងពិភពលោកតាមរយៈក្រុមហ៊ុនលក់ភេសជ្ជៈមានជាតិស្ករ ដែលក្នុងប្រទេសខ្លះមានការបង្កើតក្រុមហ៊ុនលក់ភេសជ្ជៈមានជាតិស្ករស្រដៀងទៅ Coca cola។ ប៉ុន្តែ មានប្រទេសជាច្រើនដែលទទួលស្គាល់ថា ជាតិស្ករមានគ្រោះថ្នាក់ដូច ជក់បារីដែរ ហើយបានដំឡើងពន្ធលើស្ករ។ នៅកម្ពុជា ក្រសួងសុខាភិបាលទទួលស្គាល់ថាជាតិស្ករមានគ្រោះថ្នាក់ ប៉ុន្តែមធ្យោបាយផ្សព្វផ្សាយរបស់ក្រសួងនៅចាញ់មធ្យោបាយផ្សព្វផ្សាយរបស់ក្រុមហ៊ុនលក់ភេសជ្ជៈមានជាតិស្ករ ដែលមានទូរទស្សន៍ជាច្រើនជួយផ្សាយ។ ការផ្សព្វផ្សាយថា អ្នកបានទទួលប្រាក់រង្វាន់ពីក្រុមហ៊ុនលក់ភេសជ្ជៈមានជាតិស្ករស្រក់ទឹកភ្នែករំភើបអរគុណក្រុមហ៊ុន ប៉ុន្តែប្រាក់រង្វាន់នោះបានមកពីអ្នកហូបភេសជ្ជៈផ្សេងទៀតដែលប្រឈមនឹងជំងឺទឹកនោមផ្អែមនិងជំងឺផ្សេងទៀត ហើយក្រុមគ្រួសារអ្នកហូបភេសជ្ជៈទាំងនោះនឹងចំណាយថវិកាព្យាបាលជំងឺច្រើនជាង ៣ដងប្រាក់ចំណេញរបស់ក្រុមហ៊ុន ដូចអ្វីដែលកំពុងកើតមានឡើងនៅសហអាមេរិកនិងប្រទេសផ្សេងទៀត។ ប្រជាជនកម្ពុជាអាចត្រូវការពេលវេលាខ្លះដើម្បីទទួលស្គាល់ថា ជាតិស្ករពិតជាផ្ដល់ផលអាក្រក់ដល់សុខភាព។

ច្បាប់ស្ដីពីកិច្ចការពារអ្នកប្រើប្រាស់និងច្បាប់ស្ដីពីសុវត្ថិភាពម្ហូបអាហារនឹងក្លាយជាមូលដ្ឋានគតិយុត្តសម្រាប់ការពារផលប្រយោជន៍និងសុខភាពរបស់ប្រជាជនកម្ពុជាពីការបរិភោគអាហារដែលបង្កផលប៉ះពាល់ដល់សុខភាព៕

*ក.ស.វ. - ក្រុម ២*

## ៣- ការធ្វើបច្ចុប្បន្នកម្មគោលការណ៍ណែនាំស្តីពី

## នីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត

យោងតម្រូវការចាំបាច់ គណៈកម្មការមួយត្រូវបានបង្កើតឡើង ដើម្បីធ្វើបច្ចុប្បន្នកម្មគោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដោយសេចក្តីសម្រេចលេខ០៦ សសរ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មការធ្វើបច្ចុប្បន្នកម្មគោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។ គណៈកម្មការនេះមាន ឯកឧត្តម **ឆយ អូន** អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) ជាសមាជិក ហើយ ឯកឧត្តម **សួង លាងហៃ** សមាជិក ក.ស.វ. និង ឯកឧត្តម **អ៊ុន វ៉ាល់ឡឺរ៉ូ** អគ្គលេខាធិការ ក.ស.វ. ជាសមាជិកអនុគណៈកម្មការរៀបចំខ្លឹមសារ និងទម្រង់។

ភារកិច្ចរបស់គណៈកម្មការ គឺសិក្សាស្រាវជ្រាវធ្វើបច្ចុប្បន្នកម្មគោលការណ៍ណែនាំស្តីពី នីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ ហើយដែលបាននិងកំពុងអនុវត្តរហូតមកដល់ពេលនេះ ឲ្យស្របទៅនឹងបរិបទនៃការកែទម្រង់ដែលកាន់តែស៊ីជម្រៅទៅៗនាពេលបច្ចុប្បន្ន និងជាពិសេសឲ្យស្របទៅនឹងព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី និងអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី។

តាមគោលការណ៍ណែនាំឆ្នាំ២០១៣ រាល់សេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលរៀបចំដោយក្រសួងស្ថាប័នជុំវិញរាជរដ្ឋាភិបាល ត្រូវបញ្ជូនមកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាកែសម្រួលមុននឹងដាក់ឆ្លងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីទៅតាមយន្តការអង្គប្រជុំជំនាញបច្ចេកទេស អង្គប្រជុំអន្តរក្រសួង និងអង្គប្រជុំត្រួតពិនិត្យចុងក្រោយជាដើម។ ប៉ុន្តែនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ទីស្តីការគណៈរដ្ឋមន្ត្រីបានចេញសេចក្តីជូនដំណឹងលេខ២០២៥ សជណ ជម្រាបជូនគ្រប់ក្រសួង ស្ថាប័ននានា ដែលមានបំណងតាក់តែងសេចក្តីព្រាងច្បាប់ ឬអនុក្រឹត្យ ឬលិខិតបទដ្ឋាននានារបស់រាជរដ្ឋាភិបាល ត្រូវមានការចូលរួមពីក្រុមប្រឹក្សាអ្នកច្បាប់ តាំងពីដំណាក់កាលចាប់ផ្តើមរៀបចំនៅតាមក្រសួង ស្ថាប័ននានា រហូតដល់សេចក្តីព្រាងអត្ថបទច្បាប់ ឬអនុក្រឹត្យ ឬលិខិតបទដ្ឋានទាំងនោះ ត្រូវបានឆ្លងសម្រេចពីក្រសួងស្ថាប័នសាមី។ តាមរយៈសេចក្តីសម្រេចនេះ សេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលរៀបចំដោយក្រសួង ស្ថាប័ន អាចប្រជុំពិនិត្យពិភាក្សា ជាអន្តរក្រសួង នៅតាមក្រសួង ស្ថាប័នសាមី មិនចាំបាច់ឆ្លងយន្តការពិនិត្យពិភាក្សានៅទីស្តីការគណៈរដ្ឋមន្ត្រីទេ។

នៅឆ្នាំ២០១៦ ទាក់ទងនឹងការរៀបចំលិខិតបទដ្ឋានគតិយុត្តនេះដែរ រាជរដ្ឋាភិបាលបានចេញសេចក្តីសម្រេចលេខ១៣២ សសរ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបង្កើតក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត សម្រេចឲ្យគ្រប់ក្រសួង ស្ថាប័នបង្កើតក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តធ្វើរបាយការណ៍វាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត សម្រាប់ជាមូលដ្ឋានរៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត។

ដោយឡែកនៅក្នុងនីតិកាលទី៦ នៃរដ្ឋសភានេះ ព្រឹត្តិការណ៍សំខាន់មួយទៀត គឺការបង្កើតនិងការដាក់ឱ្យដំណើរការនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់(ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩៣២ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់) ដែលមានភារកិច្ចចម្បងមួយក្នុងចំណោមភារកិច្ចផ្សេងទៀត គឺផ្តួចផ្តើមគំនិតតាក់តែង ឬផ្តល់យោបល់លើការរៀបចំសេចក្តីព្រាងច្បាប់ និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតមករាជរដ្ឋាភិបាល ហើយ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតរបស់រាជរដ្ឋាភិបាល ក្នុងដំណាក់កាលនៃដំណើរការនីតិវិធីធ្វើច្បាប់កំពុងស្ថិតក្នុងក្របខណ្ឌអំណាចនីតិប្រតិបត្តិ។

យោងតាមការអនុវត្តថ្មីៗខាងលើ និងយោងតាមអាយុកាលនៃការអនុវត្តសារាចរស្តីពីការអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលមានជាង ១០ ឆ្នាំ (២០១៣-២០១៩) មកហើយនេះ ការធ្វើបច្ចុប្បន្នកម្មគោលការណ៍ណែនាំគឺជាប្រការចាំបាច់ ដែលត្រូវធ្វើយ៉ាងណាឱ្យការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត នៅតែបន្តទៅមុខដោយរលូន មានការឯកភាព មានការចូលរួមយ៉ាងទូលំទូលាយ ដើម្បីលើកស្ទួយរបបប្រជាធិបតេយ្យ សេរីពហុបក្ស និងពង្រឹងប្រសិទ្ធភាពការងាររបស់រាជរដ្ឋាភិបាលក្នុងការស្ថាបនា និងអភិវឌ្ឍប្រទេសជាតិឱ្យចម្រើនរុងរឿង។

ទោះបីសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត រៀបចំឡើងដោយក្រសួង ស្ថាប័នទីទៃពីគ្នាក៏ដោយ ទោះបីជានីតិវិធីនៃការពិនិត្យសេចក្តីព្រាងធ្វើនៅតាមក្រសួង ស្ថាប័ន សាមីក៏ដោយ ក៏សេចក្តីព្រាងនៃអត្ថបទទាំងនោះ ជាចុងក្រោយត្រូវតែដាក់ចូលមកទីស្តីការគណៈរដ្ឋមន្ត្រី ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល ដើម្បីពិនិត្យរៀបចំដាក់ជូនសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីដែរ។ បានសេចក្តីថារាល់សេចក្តីព្រាងច្បាប់ និងអនុក្រឹត្យ រួមទាំងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតរបស់រាជរដ្ឋាភិបាល ដែលក្រសួង ស្ថាប័ននានាមានភារកិច្ចរៀបចំតាក់តែងទៅតាមវិស័យរៀងៗខ្លួន ដោយក្រុមការងាររៀងៗខ្លួន គឺធ្វើឡើងក្នុងនាមរាជរដ្ឋាភិបាល សម្រាប់ដាក់ជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។ ដូច្នេះ អត្ថបទទាំងនោះ ត្រូវតែមានការឯកភាព ជាពិសេសលើវិធាននិងទម្រង់នៃការតាក់តែង ហើយនិងនីតិវិធីនៃការពិនិត្យពិភាក្សាផងដែរ។

ការធ្វើបច្ចុប្បន្នកម្មគោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត សំដៅធ្វើយ៉ាងណាប្រមូលផ្តុំនីតិវិធី និងវិធានថ្មីៗបញ្ចូលក្នុងសៀវភៅតែមួយ និងកែសម្រួលនីតិវិធី និងវិធានចាស់ឱ្យស្របតាមបរិបទថ្មីនៃការអភិវឌ្ឍប្រទេសជាតិ។

សៀវភៅគោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតមានពីរផ្នែក។ ផ្នែកទីមួយ គឺសារាចរស្តីពីការអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត និងផ្នែកទីពីរគឺគោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលមានភ្ជាប់ជាមួយនឹងសារាចរនោះ។

សារាចរណែនាំឱ្យគ្រប់ក្រសួង ស្ថាប័ន ពង្រឹងនិងជំរុញអង្គភាពនីតិកម្មក្រោមឱវាទឱ្យដំណើរការបានសកម្មក្នុងការរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ឱ្យរៀបចំគម្រោងកម្មវិធីតម្រូវការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតផ្ញើមកទីស្តីការគណៈរដ្ឋមន្ត្រី យ៉ាងយូរនៅដំណាច់ខែវិច្ឆិកានៃ

ឆ្នាំនីមួយៗ ដើម្បីរៀបចំជាបញ្ជីកម្មវិធីនៃការរៀបចំសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច សម្រាប់ឲ្យក្រសួង ស្ថាប័នទាំងអស់អនុវត្តទៅតាមគោលការណ៍ណែនាំដែលមានភ្ជាប់ជាមួយសារាចរនោះ។

ចំពោះការណែនាំ គណៈកម្មការធ្វើបច្ចុប្បន្នកម្មមិនមានការកែប្រែអ្វីឡើយ គ្រាន់តែមានការកត់សម្គាល់ទៅលើការពង្រឹងការអនុវត្តការណែនាំឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀតតែប៉ុណ្ណោះ។ អ្វីដែលជាការយកចិត្តទុកដាក់ខ្លាំងរបស់ក្រុមការងារ គឺដំណើរការនៃរៀបចំសេចក្ដីព្រាងដើម ដោយបញ្ចូលវិធានថ្មីៗ សំដៅធ្វើយ៉ាងណាឲ្យការរៀបចំមានការចូលរួមទូលំទូលាយ មានការប្រជុំពិនិត្យពិភាក្សា សិក្សាស្រាវជ្រាវ វាយតម្លៃច្បាស់លាស់ពីផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត។

ជាទូទៅចំពោះទម្រង់នៃសេចក្ដីព្រាង គឺមិនមានការកែប្រែទេ គ្រាន់តែមានការសម្របសម្រួលពាក្យពេចន៍ ឃ្លាប្រយោគទៅតាមនីតិវិធីដែលមានការប្រែប្រួល បន្ទាប់ពីការចូលជាធរមាននៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីឆ្នាំ២០១៨ និងអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្ដីការគណៈរដ្ឋមន្ត្រីឆ្នាំ២០១៨ ជាពិសេសពាក់ព័ន្ធដល់អវត្តមាននៃអគ្គលេខាធិការរាជរដ្ឋាភិបាលដែលពីមុន មានតួនាទីស្នូលក្នុងដំណើរការនៃការពិនិត្យ និងពិភាក្សាសេចក្ដីព្រាង និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដាក់ឆ្លងអង្គប្រជុំគណៈរដ្ឋ មន្ត្រី។

គណៈកម្មការ ជាពិសេសអនុគណៈកម្មការរៀបចំខ្លឹមសារនិងទម្រង់បានធ្វើការប្រជុំរៀងរាល់សប្ដាហ៍ ប្រជុំពិនិត្យពិភាក្សារួមក្នុងគណៈកម្មការធំផង និងក្នុងអនុគណៈកម្មការរៀបចំខ្លឹមសារ និងទម្រង់ខ្លួនឯងផង រហូតមកដល់ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ បានចំនួន ១៣លើក និងបានរៀបចំសេចក្ដីព្រាងគោលការណ៍ណែនាំស្ដីពីនីតិវិធី និងវិធាននៃការតាក់តែងសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត(បច្ចុប្បន្នកម្ម) ដាក់ជូនគណៈកម្មការធ្វើបច្ចុប្បន្នកម្ម ដើម្បីពិនិត្យនិងពិភាក្សាជាបន្តរួចរាល់ហើយ៕

*ក.ស.វ. - ក្រុម ១*

**គតិបណ្ឌិត**

" ធ្វើអ្វីឲ្យស្បាន់ ធ្វើអ្វីឲ្យបាន ធ្វើអ្វីឲ្យផ្ទង់
ធ្វើអ្វីឲ្យត្រូវ ធ្វើអ្វីឲ្យត្រង់ ធ្វើអ្វីឲ្យគង់
ធ្វើអ្វីឲ្យគាប់។ "

សម្ដេចព្រះមហាសង្ឃរាជា - **ជួន ណាត ជោតញ្ញាណោ**

# IV- ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំឆមាសទី១ ឆ្នាំ២០១៩*




របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ **ប្រចាំឆមាសទី១ឆ្នាំ២០១៩** នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៩ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលសុន** អនុប្រធានប្រចាំការក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង នៃ ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## I- ស្មារតីអង្គប្រជុំនិងសន្និដ្ឋាន

ក្នុងឆ្នាំ២០១៩ សេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា បាននឹងកំពុងជួបប្រទះនឹងព្រឹត្តិការណ៍មួយចំនួនដូចជា ការចាប់ផ្តើមនីតិវិធីដកការអនុគ្រោះពន្ធរបស់សហគមន៍អឺរ៉ុប ជំងឺប៉េស្តជ្រូកអាហ្វ្រិក ការបាក់រលំសំណង់អគារនៅខេត្តព្រះសីហនុ និងគ្រោះទឹកជំនន់តាមបណ្តាខេត្ត ។ល។ លើសពីនេះទៀត សេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ក៏ទទួលរងឥទ្ធិពលពីសង្គ្រាមពាណិជ្ជកម្មសហរដ្ឋអាមេរិក-ចិន និងភាពតានតឹងនៅមជ្ឈិមបូព៌ា។

ទោះជាមានបញ្ហាប្រឈមខ្លះៗយ៉ាងណាក៏ដោយ ក៏តួលេខម៉ាក្រូសេដ្ឋកិច្ចកម្ពុជានាឆមាសទី១ ឆ្នាំ២០១៩ នៅតែបង្ហាញការចាក់គ្រឹះរឹងមាំនៅឡើយ។ កំណើនសេដ្ឋកិច្ចឆ្នាំ២០១៩ ត្រូវបានព្យាករណ៍ ៧,១% រីឯលទ្ធផលជាក់ស្តែង បើប្រៀបធៀបឆមាសទី១ដូចគ្នាឆ្នាំ២០១៩ និងឆ្នាំ២០១៨ សូចនាករសំខាន់ៗមួយចំនួនមានបម្រែបម្រួលដូចខាងក្រោម៖

១.អត្រាអតិផរណាមានកម្រិតក្រោម ២% បើប៉ាន់ស្មានដល់ចុងឆ្នាំ អតិផរណានឹងស្ថិតក្រោម៣%។

២.ផលិតកម្មវាយនភណ្ឌនិងស្បែកជើងកើន ១៣,៦% សូចនាករនេះមានការប្រឈម និងមិនអាចប៉ាន់ស្មានច្បាស់លាស់បាននាពេលខាងមុខ អាស្រ័យលើលក្ខខណ្ឌពាណិជ្ជកម្មអន្តរជាតិ។

៣.ការនាំចេញកើន ១៥,៣% សូចនាករនេះពឹងផ្អែកខ្លាំងលើការនាំចេញផលិតផលកម្មន្តសាល វាយនភណ្ឌ និងស្បែកជើង។

៤.ការនាំចូលកើន ២២,៨% សូចនាករនេះពឹងផ្អែកខ្លាំងលើការនាំចេញ និងការវិនិយោគ ព្រោះថាមួយភាគធំនៃការនាំចូលជាទំនិញវិនិយោគនិងមួយផ្នែកតូចប៉ុណ្ណោះជាទំនិញសម្រាប់ប្រើប្រាស់ ដូច្នេះអាស្រ័យលើលក្ខខណ្ឌពាណិជ្ជកម្មអន្តរជាតិ និងបរិយាកាសវិនិយោគក្នុងប្រទេស។

៥.ចំណូលថវិកាជាតិកើន ១៩,៦% និងចំណាយថវិកាជាតិកើន ៨,១% ទោះបីសូចនាករទាំងពីរជាឧបករណ៍និងគោលដៅនៃគោលនយោបាយសារពើពន្ធក្នុងកម្រិតណាមួយក៏ដោយ អាស្រ័យលើសកម្មភាពធុរកិច្ចក្នុងប្រទេស និងពាណិជ្ជកម្មអន្តរជាតិ។

---

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ។ អ្នកប្រើប្រាស់ទិន្នន័យអាចទាញយកតួលេខពីតារាងតាមសេចក្តីត្រូវការរបស់ខ្លួន។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរនិងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ ( Excel ) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

៦.យោងតាមស្ថានភាពរូបិយវត្ថុ រូបិយវត្ថុទូទៅ M2[1] កើន ២១,៣% M1 កើន ១៨,០% ឥណទានពីធនាគារពាណិជ្ជកើន ២៧,៩% និងទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធកើន ២៥,០%។ តួលេខទាំងនេះ បង្ហាញថាវិស័យរូបិយវត្ថុ និងធនាគារ កម្ចីនិងបញ្ញើ លំហូររូបិយវត្ថុនិងវិនិយោគ នៅមានភាពរឹងមាំនៅឡើយ។

រូប I. ១. អត្រាកំណើននៃសូចនាករសេដ្ឋកិច្ច សង្គមកិច្ចចម្បងៗនៃកម្ពុជា ក្នុងឆមាសទី១ ២០១៩ (ធៀបនឹងឆមាសទី១ ឆ្នាំ២០១៨)




យ៉ាងណាមិញ កម្ពុជានឹងត្រូវពុះពារបញ្ហាប្រឈមមួយចំនួន ក្នុងរយៈពេលខ្លីនិងមធ្យមខាងមុខ ដែលគួរពញ្ញាក់អារម្មណ៍ ដូចជា ទិសដៅនាំចេញមានដែនកំណត់ លំហូរទេសចរពីអាមេរិកនឹងអឺរ៉ុបធ្លាក់ចុះ សេដ្ឋកិច្ចប្រទេសចិននិងពិភពលោកមានសញ្ញាថមថយ គ្រោះធម្មជាតិ ឬឧបត្តិហេតុផ្សេងៗ ដែលតម្រូវឱ្យមានវិធានការសមស្រប ទាន់ហេតុការណ៍ មានលក្ខណៈបត់បែន ដោយស្មារតីចូលរួមនិងទទួលខុសត្រូវខ្ពស់។

## II- ការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

| ល.រ | សូចនាករ | ធៀបនឹងឆមាសមុន | ធៀបនឹងឆមាសដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ១ | ក្រុមភោជនីយដ្ឋាន | ៣,៦៥% | ៦,៦៥% |
| ២ | ឧស្ម័ន | ៤,០៥% | ៦,៧៥% |
| ៣ | អ្នកទទួលការងារធ្វើថ្មីតាមរយៈក្រសួងការងារនិងក្រុមហ៊ុន<br>បានក្នុងប្រទេស | - ១០% | - ៧% |
| ៤ | ការនាំចេញផលិតផលនេសាទ | - ៣៤,៨% | - ១៩,១% |
| ៥ | ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | 0% | - ៤៩% |
| ៦ | ឧស្សាហកម្មធុនតូច និងសប្បកម្ម (បន្ត) | - ៣៩% | - ៨៤% |

[1] M2 = M1 + ប្រាក់បញ្ញើមានការកំណត់និងសន្សំ + ប្រាក់បញ្ញើជារូបិយបណ្ណ។ កំណើនសមាសធាតុរូបិយវត្ថុជាសញ្ញាណល្អនៃការលូតលាស់សេដ្ឋកិច្ច
M1 = រូបិយវត្ថុក្រៅធនាគារ + ប្រាក់បញ្ញើចរន្ត

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងអត្រាប្តូរប្រាក់

➡បើប្រៀបធៀបក្នុងឆមាសទី១ដូចគ្នាឆ្នាំ២០១៩និងឆ្នាំ២០១៨ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ កើនឡើង១,៨៨% ដែលអាចចាត់ទុកថា ជាកម្រិតទាបបើធៀបនឹងការចែងក្នុងគោលនយោបាយ (៣% - ៥%)។

តារាង១.១. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់តាមខែពីឆ្នាំ២០១៧ដល់ឆ្នាំ២០១៩

| | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា[P] | សីហា[P] | កញ្ញា[P] | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៩ | ខែដូចគ្នាឆ្នាំ | ១,៥% | ២,០% | ២,២% | ២,១% | ២,០% | ១,៤% | ២,៧% | ២,១% | ២,០% | | | | |
| ២០១៨ | ខែដូចគ្នាឆ្នាំ | ២,០% | ២,៣% | ២,៣% | ២,៧% | ២,៩% | ២,៩% | ២,៣% | ២,៦% | ២,៦% | ៣,១% | ២,៥% | ១,៦% | ២,៥% |
| ២០១៧ | ខែដូចគ្នាឆ្នាំ | ៤,៤% | ៤,០% | ៤,២% | ៣,២% | ២,៥% | ២,៣% | ២,៩% | ២,៦% | ២,៧% | ២,១% | ២,៣% | ២,២% | ២,៩% |

P: តួលេខខែ កក្កដា សីហា កញ្ញា និងប្រចាំឆ្នាំ២០១៩ ជាតួលេខព្យាករណ៍(តាមវិធីសាស្រ្ត **Decomposition**)

តារាង១.២. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (តាមក្រុមទំនិញ)

| ក្រុមទំនិញ | សន្ទស្សន៍មធ្យមឆមាសទី១ ឆ្នាំ២០១៩ | សន្ទស្សន៍មធ្យមឆមាសទី១ ឆ្នាំ២០១៨ |
|---|---|---|
| ទំនិញប្រើប្រាស់ (២៥៩ មុខ) | ១៧៦,៣% | ១៧៣,១% |
| ម្ហូបអាហារ | ២១៧% | ២១៣% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | ១៧០,៥% | ១៦១,១% |
| សម្លៀកបំពាក់ និងស្បែកជើង | ១៥០,៦% | ១៤៦,២% |
| ផ្ទះសំបែងទឹកអគ្គិសនីឧស្ម័ននិងឥន្ធនៈផ្សេងទៀត | ១២៧,៤% | ១២៥,៧% |
| គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ | ១៥២,៦% | ១៥០,៦% |
| សុខាភិបាល | ១៣៧,១% | ១៣៤,៦% |
| ការដឹកជញ្ជូន | ១១៣,៤% | ១១៦,៥% |
| ក្នុងនោះ ប្រេងសាំង | ៨៧,៧% | ៩៧,៦% |
| ទូរគមនាគមន៍ | ៦៧,៣% | ៦៧,៧% |
| ការកម្សាន្ត និងវប្បធម៌ | ១១៨,៩% | ១១៧,៩% |
| ការសិក្សា | ១៥៩,៥% | ១៥៩,២% |
| ភោជនីយដ្ឋាន | ២៨៣,៩% | ២៦៥,៧% |
| ទំនិញ និងសេវាកម្មផ្សេងៗ | ១៤៦,១% | ១៤៤,៥% |

កំណត់សម្គាល់ : គ្រាគោលគឺត្រីមាសទី៤ ឆ្នាំ២០០៦ = ១០០%

- មុខទំនិញដែលឡើងថ្លៃខ្ពស់មានឧស្ម័ន ៦,៧៥% និងសាច់មាន់ស្រស់ ៣,២៧%

➡**អត្រាប្តូរប្រាក់**: ជារួមអត្រាប្តូរប្រាក់មានស្ថេរភាព។ ប្រាក់រៀលមានការធ្លាក់ថ្លៃធៀបនឹងប្រាក់ដុល្លារនិងប្រាក់បាត ប៉ុន្តែមានការឡើងថ្លៃធៀបនឹងប្រាក់ដុង ។

| ប្រភេទ | ចុងឆមាសទី១/២០១៩ | ចុងឆមាសទី១/២០១៨ | បម្រែបម្រួល |
|---|---|---|---|
| **៛/១ដុល្លារ** | ៤ ០៦៦៛ | ៤ ០៦៣៛ | ០,១% |
| **៛/១បាត** | ១៣២៛ | ១២៣៛ | ៧,៣% |
| **៛/១ដុង** | ០,១៧៤៛ | ០,១៧៧៛ | -១,៧% |

## ៥) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិក្នុងឆមាសទី១ ឆ្នាំ២០១៩ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

➢ចំណូលអនុវត្តបានចំនួន ១១ ៤៧២,៩ ប៊ីលានរៀល គិតជាដុល្លារអាមេរិក មានចំនួន ២ ៨៦៨,២ លានដុល្លារស្មើនឹង ៥៧% នៃផែនការហិរញ្ញវត្ថុប្រចាំឆ្នាំ ក្នុងនោះ ចំណូលចរន្តមានចំនួន ១១ ៣៨៧ ប៊ីលានរៀល គិតជាដុល្លារអាមេរិក មានចំនួន ២ ៨៤៦,៧ លានដុល្លារ ស្មើនឹង ៥៨% នៃផែនការ និងចំណូលមូលធនចំនួន ៨៦,១ ប៊ីលានរៀល។

➢បើធៀបនឹងឆមាសទី១ដូចគ្នា ចំណូលថវិកាជាតិ កើនឡើង១៩,៦% ដែលក្នុងនោះចំណូលចរន្ត កើនឡើង ២១,៤%។

➢ ក្នុងចំណូលចរន្ត :ចំណូលសារពើពន្ធក្នុង៦ខែដើមឆ្នាំនេះអនុវត្តបានចំនួន ១០ ១៨៦,៨ ប៊ីលានរៀល គិតជាដុល្លារ អាមេរិកមានចំនួន ២ ៥៤៦,៧ លានដុល្លារ ស្មើនឹង៦០% នៃផែនការប្រចាំឆ្នាំ។ បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០១៨ចំណូលសារពើពន្ធ កើនឡើង ២១,២% ដែលក្នុងនោះ ពន្ធនិងអាករគយ កើនឡើង ២៥,៧% (តាមអគ្គនាយកដ្ឋានគយនិងរដ្ឋាករ កើនឡើង៣០%) និងចំណូលពន្ធដារកើនឡើង ១៥,៥% (តាមអគ្គនាយកដ្ឋានពន្ធដារ កើនឡើង១៨,៨%)។

ក្រាហ្វ ២.១. សមាសធាតុចំណូលសារពើពន្ធតាមឆមាស (២០១៣-២០១៩)




### តារាង២.១. សមាសភាពនៃចំណូលចរន្ត

| មុខចំណូល | អនុវត្ត ផែនការ | %Δធៀបនឹង ឆ.១ឆ្នាំ ២០១៨ | មុខចំណូល | អនុវត្ត ផែនការ | %Δធៀបនឹង ឆ.១ឆ្នាំ ២០១៨ |
|---|---|---|---|---|---|
| **ចំណូលសារពើពន្ធ(រតនាគារ)** | ៦០% | +២១,២% | **ចំណូលមិនមែនសារពើពន្ធ** | ៤៤% | +២៤,២% |
| ✓ពន្ធនិងអាករគយ(**អ.នាគយ និងរដ្ឋាករ**) | ៦៥% | +២៥,៧% | ✓កាស៊ីណូ | ៤% | –៨៤,២% |
| | | | ✓អាជ្ញាបណ្ណក្នុងស្រុក | ២៥% | –២៥,៩% |
| -ពន្ធគយ (របបនាំចូល) | ៦៨% | +៣៣,៨% | ✓កម្រៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ | ៣៣% | +៣៩,០% |
| -អាករពិសេសលើរបបនាំចូល | ១១២% | +៣១,១% | ✓នេសាទ | ៤៩% | +១៥៧,៥% |
| -អាករលើតម្លៃបន្ថែមរបបនាំចូល | ៧៩% | +២៨,៦% | ✓ រុក្ខាប្រមាញ់ | ៥៤% | +៥៧,៣% |

| | | | | | |
|---|---|---|---|---|---|
| -អាករនាំចេញ | ៥១% | +៤,៣% | ✓សម្បទានរ៉ែ | ៣៩% | +៤០,៥% |
| -អាករបន្ថែមលើផលិផលតេលសិលា | ៦៦% | +២៦,៥% | ✓អាកាសចរណ៍ស៊ីវិល | ២៦% | –១៧,១% |
| | | | ✓ ផលទុនទេសចរណ៍ | ៤១% | +៦,១% |
| ✓ចំណូលពន្ធដារ(**អ.នា ពន្ធដារ**) | ៥៥% | +១៨,៨% | ✓ត្រួតពិនិត្យគុណភាពផលិតផល | ១៦% | +៣៨៦,៥% |
| -ពន្ធលើប្រាក់បៀវត្ស | ៤១% | +៤,៥% | ✓ ជួលសហគ្រាស សម្ភារៈ | ៤៣% | +២៦០,៦% |
| - ពន្ធលើប្រាក់ចំណេញ | ៦៥% | +១៧,៨% | | | |
| - អាករលើតម្លៃបន្ថែម | ៤៦% | +១៨,១% | | | |
| -អាករពិសេស | ៥១% | +៩,០% | | | |
| -ចំណូលផ្សេងៗ | ៦២% | +១៨% | | | |
| -ថវិកាខេត្ត–រាជធានី | ៥៤% | +៤២,៩% | | | |

➢ចំណាយថវិកាជាតិក្នុងឆមាសទី១ឆ្នាំ២០១៩ អនុវត្តបានចំនួន ៧ ២៩២,៥ ប៊ីលានរៀល គិតជាដុល្លារអាមេរិក មានចំនួន ១ ៨២៣,១ លានដុល្លារ ស្មើនឹង ៣៦% នៃផែនការប្រចាំឆ្នាំ ក្នុងនោះ ចំណាយចរន្តសម្រេចបានចំនួន ៦ ៤២២,៤ ប៊ីលានរៀល ស្មើនឹង ៣៦% នៃផែនការ និងចំណាយមូលធនមានចំនួន ៨៧០,២ប៊ីលានរៀល។

➢បើប្រៀបធៀបឆមាសទី១ដូចគ្នាឆ្នាំ២០១៨ចំណាយថវិកាជាតិកើនឡើង៨,១%ក្នុងនោះៈចំណាយចរន្តកើនឡើង៧,៨% និងចំណាយមូលធន កើនឡើង១០,៧% ។

➢ថវិកាជាតិនាឆមាសទី១ឆ្នាំ២០១៩ មានអតិរេកចំនួន ៤ ១៨០,៣ ប៊ីលានរៀល ស្មើនឹង ១ ០៤៥,១ លានដុល្លារ ស.រ.អា។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុនាចុងឆមាសទី១ឆ្នាំ២០១៩មានលក្ខណៈដូចខាងក្រោមៈ

➢រូបិយវត្ថុ M2 មានចំនួន ៩៦ ២៤៧,៦ ប៊ីលានរៀល កើនឡើង ២១,៣% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៨។

ក្រាហ្វ៣.សមាសធាតុរូបិយវត្ថុនាចុងឆមាសទី១ឆ្នាំ២០១៩




➢ការកើនឡើងនៃ M2 នេះបណ្តាលមកពីកំណើននៃរូបិយវត្ថុក្រៅធនាគារ១៦,៩% ប្រាក់បញ្ញើចរន្ត ២៧,៥% ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ ២៤,០% និងប្រាក់បញ្ញើជារូបិយបណ្ណ ២១,៧%។

➢ចំនួនប្រាក់រៀលនៅក្នុងនិងក្រៅធនាគារសរុបមានចំនួន ១៥,២% នៃរូបិយវត្ថុ M2 រីឯប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៤,៨%។

➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** មានចំនួន ១១ ២២៩ លានដុល្លារ មានការ កើនឡើង២៥% ធៀបនឹងឆមាសទី១ឆ្នាំ២០១៨

➢**ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិនៃកម្ពុជា** ជាទូទៅមានការកើនឡើង ដោយក្នុងឆមាសទី១ឆ្នាំ២០១៩ មានចំនួន ៣០ ៨៦៨,១ ប៊ីលានរៀល កើនឡើង ៧,០% បើធៀបនឹងអំឡុងពេលដូចគ្នា ឆ្នាំ២០១៨។

➢**ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ** មានចំនួន ៩៥ ០៣៣,០ ប៊ីលានរៀល កើនឡើង២៧,៩% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៨។

➢**ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** (សម្រាប់ឆមាសទី១ឆ្នាំ២០១៩ តួលេខមិនទាន់ទទួលបាន)

➤ *អត្រាការប្រាក់ប្រចាំឆ្នាំ*

| ប្រភេទអត្រាការប្រាក់ | ចុងឆមាសទី១ ឆ្នាំ២០១៩ | ចុងឆមាសទី១ ឆ្នាំ២០១៨ | បម្រែបម្រួល |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,២% | ៦,០% | ២,៧% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៧% | ៤,៤% | ៥,៣% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៣,១% | ១១,៤% | ១៥,0% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ៨,៧% | ១១,៣% | -២៣,១% |
| កម្ចីជារៀលនៅអម្រឹត | ១៨% | ១៨% | 0% |
| កម្ចីជារៀលនៅហត្ថាកសិករ | ១៨% | ១៨% | 0% |
| កម្ចីជារៀលនៅប្រាសាក់ | ១៦,៩% | ១៥,៧% | ៧,៦% |

## ៤) ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

ក្នុងឆមាសទី១ ឆ្នាំ២០១៩ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម :

➡ កសិកម្ម

➤ តារាងខាងក្រោមបង្ហាញផ្ទៃដីដំណាំផ្សេងៗ ឆ្នាំ ២០១៧ ២០១៨ និង៦ខែដើមឆ្នាំ២០១៩។

| *ប្រភេទដំណាំ* | *ឆមាសទី១ –២០១៩* | *ឆ្នាំ២០១៨* | *ឆ្នាំ២០១៧* |
|---|---|---|---|
| ផ្ទៃដីដាំស្រូវវស្សា (ពាន់ហិកតា) | ១២៨៤,0 | ២ ៧៣៥,៨ | ២៦៥៨ |
| ផ្ទៃដីដាំពោត (ពាន់ហិកតា) | ១១៧,៩ | ១៩៣,៨ | ២០៧,២ |
| ផ្ទៃដីដាំដំឡូងឈើ (ពាន់ហិកតា) | ៤១៧,៩ | ៦០៣,៣ | ៥៥៨,៧ |
| ផ្ទៃដីដាំដំឡូងជ្វា (ពាន់ហិកតា) | ១,៦ | ២,៨ | ៣,៣ |
| ផ្ទៃដីដាំបន្លែគ្រប់មុខ (ពាន់ហិកតា) | ១៧,៩ | ៣២,៣ | ៣០,៧ |
| ផ្ទៃដីដាំសណ្តែកបាយ (ពាន់ហិកតា) | ១៦,៥ | ២៨,៧ | ៣៣,៥ |
| ផ្ទៃដីដាំសណ្តែកដី (ពាន់ហិកតា) | ៥,៣ | ១១,១ | ១២,៥ |
| ផ្ទៃដីដាំសណ្តែកសៀង (ពាន់ហិកតា) | ១,៣ | ៤៣,៨ | ៤០,២ |
| ផ្ទៃដីដាំកៅស៊ូសរុប (ពាន់ហិកតា)<br>ក្នុងនោះ ផ្ទៃដីចៀរជ័រ | ៤៣៤,0<br>២៣៣,២ | ៤៣៦,៧<br>២០១,៩ | ៤៣៦,៣<br>១៧០,២ |

➤ ផលិតផលនេសាទមានចំនួន ៣៣៨,៦ **ពាន់តោន** កើនឡើង ៦% បើធៀបនឹងឆមាសទី១ដូចគ្នា ឆ្នាំ ២០១៨។

➡ ឧស្សាហកម្ម

➤ ថាមពលអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៥ ៤៩៤,៩ GWh កើនឡើង២៣% ធៀបនឹងឆមាសទី១ឆ្នាំ២០១៨។ ក្នុងនោះវារីអគ្គិសនីមានចំនួន ៩៤៣,៩ GWh ថយចុះ៤២% អគ្គិសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន ២ ២០១,៨ GWh កើនឡើង១៥% អគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតមានចំនួន ៥៨៨,២ GWh កើនឡើង ២០៩% និងអគ្គីសនីនាំចូលពីប្រ ទេសជិតខាងដោយ**EDC**មានចំនួន ១ ៧៦១,0 GWh កើនឡើង ១៤០% ។

➤ ផលិតកម្មវាយនភណ្ឌនិងស្បែកជើង ៤ ២៧៧,៨ លានដុល្លារ កើនឡើង១៤% ធៀបនឹងឆមាសទី១ឆ្នាំ ២០១៨។

➢ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាសនៅក្រសួងឧស្សាហកម្ម:

| ប្រភេទ | ចំនួន :ឆមាសទី១ ឆ្នាំ២០១៩ | ចំនួន:ឆមាសទី១ ឆ្នាំ២០១៨ | បម្រែបម្រួល |
|---|---|---|---|
| រោងចក្រថ្មីដែលបានចុះបញ្ជី | ១៦៩ | ៧៤ | +១២៨% |
| ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១ ៦៥៧ | ១ ៥៩៦ | +៤% |
| ឧស្សាហកម្មធុនតូចនិងសិប្បកម្ម (បើកថ្មី) | ៣៩ | ៧៧ | -៤៩% |
| ឧស្សាហកម្មធុនតូចនិងសិប្បកម្ម (បន្ត) | ២៥ | ១៥៩ | -៨៤% |

➡ **សំណង់**

➢សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៧ ០១៥,១ ពាន់ម² កើនឡើង៣១% បើធៀបនឹងឆមាសទី១ ឆ្នាំ២០១៨។ ការអនុញ្ញាតនេះ ជាទឹកប្រាក់មានចំនួន ៣ ៣៩៣,៨ លានដុល្លារ កើនឡើង៥៨% បើធៀបនឹង៦ខែដើមឆ្នាំ២០១៨។ ក្នុងនោះប្រភេទសំណង់សំខាន់ៗមាន :

| *ប្រភេទសំណង់* | ពាន់ម² :ឆមាសទី១ ឆ្នាំ២០១៩ | ពាន់ម² :ឆមាសទី១ ឆ្នាំ២០១៨ | បម្រែបម្រួល |
|---|---|---|---|
| លំនៅឋាន | ៣ ៧៣៥,២ | ២ ២៩១,៣ | +៦៣% |
| ឧស្សាហកម្ម | ១ ០២០,៤ | ៣២២,៤ | +២១៦% |
| ពាណិជ្ជកម្ម | ១ ៧៣០,០ | ៥០៤,៣ | +២៤៣% |
| ទេសចរណ៍ | ៤៥៨,៨ | ២ ១០៣,៣ | -៧៨% |
| ... | | | |
| អនុញ្ញាតសរុប | ៧ ០១៥,១ | ៥ ៣៥៣,៦ | +៣១% |

➢ **ដូច្នេះ** ក្នុងការអនុញ្ញាតឆមាសទី១ឆ្នាំនេះ សំណង់ដែលពេញនិយមគឺលំនៅឋាន (៥៣,២% នៃផ្ទៃក្រឡាសរុប) និងពាណិជ្ជកម្ម (២៤,៧% នៃផ្ទៃក្រឡាសរុប)។

➡ **សេវាកម្ម និងទេសចរណ៍**

➢ការចុះបញ្ជី និងលុបចេញពីបញ្ជី :

| *ប្រភេទ* | *ចំនួន* :ឆមាស១ ឆ្នាំ ២០១៩ | *ចំនួន* :ឆមាស១ ឆ្នាំ ២០១៨ | បម្រែបម្រួល |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៦ ៧៤៨ | ៥ ៧៦៦ | +១៧% |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៥២ | ៦៦ | -២១% |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៥ ១៨៦ | ១ ៨០៨ | +១៨៧% |

➡ **ការងារ**

| ប្រភេទ | ឆមាសទី១ ឆ្នាំ ២០១៩ (នាក់) | ឆមាសទី១ ឆ្នាំ ២០១៨ (នាក់) | បម្រែបម្រួល |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារធ្វើ( ទីភ្នាក់ងារមុខរបរ និងការងារ ) | ៨ ៨០៨ | ៨ ០៤៦ | +៩% |
| អ្នកទទួលបានការធ្វើតាមរយៈក្រសួងនិងក្រុមហ៊ុន | ៩៣ ០៤៩ | ៨៥ ៥១២ | +៩% |
| អ្នកទទួលបានការងារធ្វើក្នុងប្រទេស | ៦២ ៤០៣ | ៦៧ ០៨៤ | -៧% |
| អ្នកទទួលបានការងារធ្វើក្រៅប្រទេស | ៣០ ៦៤៦ | ១៨ ៤២៨ | +៦៦% |

## ➡ វិនិយោគ

➢ គម្រោងវិនិយោគ**អនុញ្ញាតដោយ** ក.អ.ក. (ថ្មី និងពង្រីក)

| ប្រភេទ | ឆមាសទី១ ឆ្នាំ២០១៩ | ឆមាសទី១ ឆ្នាំ២០១៨ | បម្រែបម្រួល |
|---|---|---|---|
| **អនុញ្ញាតសរុប** (លានដុល្លារ) ក្នុងនោះ : | ៥ ១៨១,២ | ៣ ៤៦៨,៩ | +៤៩% |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៦១,៩ | ៣៣៧,៨ | -៨២% |
| វិស័យឧស្សាហកម្ម | ៩២០,៦ | ៥៤៧,៤ | +៦៨% |
| ក្នុងនោះ តំបន់សេដ្ឋកិច្ចពិសេស | ៤៤៣,២ | ១៧៨,៥ | +១៤៨% |
| វិស័យទេសចរណ៍ | ៣ ៧៧៤,១ | ២០១,១ | កើនកំហុគ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ៤២៤,៧ | ២ ០៨២,៦ | -៨០% |
| **គម្រោងថ្មី និងគម្រោងពង្រីក (ចំនួន)** | ១៥៣ | ១០៦ | +៤៤% |
| **បង្កើតការងារ (ពាន់នាក់)** | ១៦៧,៣ | ៩៨,៦ | +៧០% |

➢ **ទំនិញឆ្លងកាត់តាមកំពង់ផែ** (សរុប២កំពង់ផែ)មានចំនួន៥ ០៦០,៥ពាន់តោន ថយចុះ៨% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៨។ ក្នុងនោះ :

| ប្រភេទ | ឆមាសទី១ ឆ្នាំ២០១៩ (ពាន់តោន) | ឆមាសទី១ឆ្នាំ២០១៨ (ពាន់តោន) | បម្រែបម្រួល |
|---|---|---|---|
| កំពង់ផែភ្នំពេញ | ១ ៨៦៨,៩ | ១ ៤៩២,១ | +២៥% |
| កំពង់ផែកំពង់សោម | ៣ ១៩១,៦ | ៣ ៩៧០,៥ | -២០% |

## ↳ អ្នកដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

| ប្រភេទ | ឆមាសទី១ ឆ្នាំ២០១៩(ពាន់នាក់) | ឆមាសទី១ ឆ្នាំ២០១៨(ពាន់នាក់) | បម្រែបម្រួល |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៩៥,២ | ១១២,៤ | -១៥% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៤៨៨,៨ | ៣២៤,៧ | +៥១% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៥ ២៧២,១ | ៤ ៥៩៥,៥ | +១៥% |
| អ្នកទេសចរជាតិចេញក្រៅប្រទេស | ១ ០០៥,១ | ៩៦៤,៣ | +៤% |
| អ្នកទេសចរអន្តរជាតិមកដល់កម្ពុជា | ៣ ៣៣៨,៥ | ៣ ០០១,៧ | +១១% |
| ✓តាមផ្លូវអាកាស | ២ ៣៥៣,៩ | ២ ០០៤,១ | +១៧% |
| ✓ តាមផ្លូវគោក និងទឹក | ៩៨៤,៥ | ៩៩៧,៥ | -១% |

➢ **ប្រៃសណីយ៍និងទូរគមនាគមន៍**

| ប្រភេទ | ឆមាសទី១ ឆ្នាំ២០១៩ | ឆមាសទី១ ឆ្នាំ២០១៨ | បម្រែបម្រួល |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ១១៧,១ | ១១០,៥ | ៦% |
| ក្នុងនោះទទួល | ១៣,៩ | ១៤,២ | -២% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៥៥២,៨ | ៦១៤,៦ | -១០% |
| ក្នុងនោះទទួល | ៣១៥,៧ | ៣១០,២ | ២% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ៨ ៧៤៨,៨ | ១១ ៥១៩,២ | -២៤% |
| ក្នុងនោះហៅចូល | ២ ៩៤៥,៣ | ៣៤ ៣៣,៨ | -១៤% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៣៧ ០៣១,០ | ១ ២៤០,៥ | -១០% |
| ក្នុងនោះហៅចូល | ៣៦ ៦៦៣,០ | ៤០ ៦២៥,១ | -១០% |

## ៥) ស្ថានភាពជញ្ជូនពាណិជ្ជកម្ម

យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ:

➡ការនាំចូលក្នុងឆមាសទី១ ឆ្នាំ២០១៩មានចំនួន ៣៨ ២០០ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៩ ៩៥០,០ លានដុល្លារ កើនឡើង ២២,៨% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៨។ក្នុងនោះមុខទំនិញគួរកត់សម្គាល់មាន:

| បរិយាយ | % ∆ ធៀបនឹងឆ.ទី១ ឆ្នាំ២០១៨ | បរិយាយ | %∆ ធៀបនឹងឆ.ទី១ ឆ្នាំ២០១៨ |
|---|---|---|---|
| ប្រេងសាំង | +១៩,៦% | គ្រាក់ទ័រនិងគោយន្ត(ជាគ្រឿង) | -១៣,៤% |
| ប្រេងម៉ាស៊ូត | +២៩,០% | ម៉ូតូ(ជាគ្រឿង) | +៨,៦% |
| ឧស្ម័ន | +៣០,៧% | អង្ករ | -៣៦,៨% |
| ប្រេងខ្មៅ | +១៣,៧% | ផ្លែឈើនិងបន្លែ | +៦,៦% |
| អគ្គិសនីនាំចូលដោយ EDC | +១៣៩,៥% | ជីនិងថ្នាំកសិកម្ម | +១៦២,៥% |
| ដែកសំណង់ | +៦៤,៣% | បារី | -១០,៣% |
| ស៊ីម៉ង់ត៍ | -១០,៩% | ភេសជ្ជៈ | +៤,៧% |
| គ្រឿងអេឡិចត្រូនិក | +៣២២,៧% | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +៣,៧% |
| រថយន្តសរុប (ជា ព.ល.រ) | +៦៤,៨% | | |
| រថយន្តសរុប (ជាគ្រឿង) | +៤០,២% | | |

➡**ការនាំចេញ** ក្នុងឆមាសទី១ឆ្នាំ២០១៩ មានចំនួន ២៧ ១០៩,៤ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៦ ៧៧៧,៣លានដុល្លារ (មានចំនួន៧១,០%នៃការនាំចូល) មានការ កើនឡើង ១៥,៣% ធៀបនឹងឆមាសទី១ ឆ្នាំ ២០១៨។ ក្នុងនោះមុខទំនិញសំខាន់ៗមួយចំនួនមាន

| *ទំនិញ* | %∆ ធៀបនឹងឆ.ទី១ ឆ្នាំ២០១៨ | *ទំនិញ* | %∆ ធៀបនឹងឆ.ទី១ ឆ្នាំ ២០១៨ |
|---|---|---|---|
| ផលិតផលឈើកែច្នៃ | -១៨,៣% | ផលិតផលនេសាទ | -១៩,១% |
| វាយនភណ្ឌនិងស្បែកជើង | +១៣,៦% | កៅស៊ូ | +៣,៤% |
| អង្ករ | +០,៤% | | |

*គ.ស.វ. - ក្រុម Ad-hoc*



# សេចក្តីសង្ខេបស្តីពីសមិទ្ធផលនៃការអនុវត្តកម្មវិធី
# វាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
# ចាប់ពីខែតុលា ឆ្នាំ២០១១ ដល់ខែមិថុនា ឆ្នាំ២០១៩

## ១- ប្រវត្តិ

កម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (Regulatory Impact Assessment (RIA Program) ហៅកាត់ថា "**កម្មវិធីRIA**" បានចាប់ផ្តើមនៅប្រទេសកម្ពុជា នៅឆ្នាំ២០០៨ តាមការសាកល្បងអនុវត្តវិធីសាស្ត្រRIA ក្នុងការរៀបចំប្រកាសឲ្យប្រសើរឡើងនៅអតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលជាគម្រោងមួយក្នុងកម្មវិធីពិពិធកម្មសេដ្ឋកិច្ចនៃក្រសួងពាណិជ្ជកម្ម ដើម្បីជួយដល់ឧស្សាហកម្មកម្ពុជា នៅពេលដែលសាកលលោកកំពុងមានវិបត្តិហិរញ្ញវត្ថុខ្លាំងនោះផង ហើយក៏បានទទួលផលវិជ្ជមាន។ ដោយឃើញមានអត្ថប្រយោជន៍នៃវិធីសាស្ត្រRIAដល់ការរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្ត ដែលប្រទេសសមាជិកអង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ចរួមនិងអភិវឌ្ឍន៍ (Organization for Economic Co-operation and Development-OECD) ក៏បានទទួលស្គាល់និងអនុវត្តយូរយាមកហើយ និងម្យ៉ាងវិញទៀតធនាគារអភិវឌ្ឍន៍អាស៊ីបានសិក្សាឃើញថា RIAគួរនៅទីតាំងកណ្តាលរបស់រាជរដ្ឋាភិបាលទើបមានការវិវឌ្ឍន៍លឿន ដូច្នេះ **សម្តេចវិបុលបញ្ញា សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងធនាគារអភិវឌ្ឍន៍អាស៊ី បានសម្រេចឲ្យក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ហៅកាត់ថា ក.ស.វ. (ហៅកាត់ជាភាសាអង់គ្លេស ECOSOCC) ទទួលបន្ទុកគ្រប់គ្រងគម្រោងRIAតាំងពីឆ្នាំ២០១១ ដោយមានការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាចំនួន២ ដើម្បីបង្កើតជាគម្រោងRIAក្រោមហិរញ្ញប្បទានឥតសំណងពីធនាគារអភិវឌ្ឍន៍អាស៊ី(ADB Grant No. 0224)។



ដើម្បីគាំទ្រដល់ដំណើរការដំបូងនៃគម្រោងនេះ ADB បានជួលក្រុមហ៊ុនប្រឹក្សាយោបល់មកពីប្រទេសអាល្លឺម៉ង់ឈ្មោះ POHL Consulting & Associates សម្រាប់ការបណ្តុះបណ្តាលធនធានមនុស្ស និងរៀបចំចាត់ចែងទស្សនៈកិច្ចសិក្សាដកពិសោធន៍នៅក្រៅប្រទេស ចាប់ពីឆ្នាំ២០១២ ដល់ខែកុម្ភៈ ឆ្នាំ២០១៣។ ហើយចាប់ពីខែមីនា ឆ្នាំ២០១៣មក ECOSOCC មានសមត្ថភាពអាចទទួលបន្ទុកការងារបណ្តុះបណ្តាលដល់ក្រសួងស្ថាប័នដោយខ្លួនឯងបាន។



ឯកឧត្តម យឹម ណុលសន ដឹកនាំប្រជុំជាមួយADB ក្រុមRIAតំណាងក្រសួង និងក្រុមហ៊ុនទីប្រឹក្សា ដើម្បីពិភាក្សាអំពីដំណើរការគម្រោង

គម្រោង RIA ត្រូវបានប្រកាសជាផ្លូវការកាលពីខែតុលា ឆ្នាំ២០១២ នៅក្នុងអង្គសិក្ខាសាលាមួយ ដែលមានសិក្ខាកាម៣៥០នាក់ ពីគ្រប់ក្រសួងស្ថាប័ន ផ្នែកឯកជន សង្គមស៊ីវិល ហើយវាគ្មិនជាតិ និងអន្តរជាតិ ចូលរួមធ្វើបទបង្ហាញ និងពិភាក្សាអំពីបទពិសោធនៃការអនុវត្តRIA។ សិក្ខាសាលាស្តីពីការផ្សព្វផ្សាយគម្រោង RIA ត្រូវបានរៀបចំឡើងក្រោមអធិបតីភាព ឯកឧត្តមទេសរដ្ឋមន្ត្រី **យឹម ណុលឡា** ប្រធាន ECOSOCC ក្នុងកម្មវិធីបើក និងក៏មានកិត្តិយសដ៏ខ្ពង់ខ្ពស់ដោយមានវត្តមាន **សម្តេចវិបុលបញ្ញា សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាអធិបតីក្នុងកម្មវិធីបិទ។




ឯកឧត្តមទេសរដ្ឋមន្ត្រី យឹម ណុលឡា ជាអធិបតីភាពក្នុងពិធីបើកសិក្ខាសាលាប្រកាសបើកគម្រោងRIA




សម្តេចវិបុលបញ្ញា សុខ អាន ជាអធិបតីភាពក្នុងពិធីបិទសិក្ខាសាលាប្រកាសបើកគម្រោងRIA




ឯកឧត្តម យឹម ណុលសន ថ្លែងរបាយការណ៍បើកសិក្ខាសលា និង Presentation of Mr. Kelly Bird, RIA Task Manager, ADB

ក្នុងការអនុវត្តគម្រោងRIAសាកល្បងចាប់ពីខែតុលា ឆ្នាំ២០១១ ដល់ឆ្នាំ២០១៥ មុនដំបូងមានក្រសួងចំនួន៤ ចូលរួមប៉ុណ្ណោះ គឺក្រសួងពាណិជ្ជកម្ម ក្រសួងរ៉ែនិងថាមពល (អតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល) ក្រសួងបរិស្ថាន និងក្រសួងទេសចរណ៍ និងបន្ទាប់ពីមានការវាយតម្លៃនៅពាក់កណ្តាលគម្រោងនៅខែសីហា ឆ្នាំ២០១៣មក ឃើញថាការអនុវត្តRIAផ្តល់ផលវិជ្ជមានច្រើនគួរឲ្យកត់សម្គាល់ដល់គោលការណ៍ប្រតិបត្តិល្អក្នុងនីតិវិធីរៀបចំលិខិតបទដ្ឋានគតិយុត្ត (Good Practice Regulation) ដូច្នេះនៅដើមឆ្នាំ២០១៤បានបន្ថែមចំនួន៣ គឺក្រសួងអប់រំ យុវជននិងកីឡា ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចូលរួមក្នុងគម្រោង។

ជាបន្តបន្ទាប់មកចាប់ពីឆ្នាំ២០១៥ មានក្រសួងចូលរួមបន្ថែម៦ទៀត គឺក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងសុខាភិបាល ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយក្រសួងការពារជាតិ និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានចូលរួមក្នុងត្រីមាសទី៤ ឆ្នាំ២០១៦។

បន្ទាប់ពីហិរញ្ញប្បទានឥតសំណងលេខ០២២៤បានបញ្ចប់នៅត្រឹមដំណាច់ឆ្នាំ២០១៥ ធនាគារអភិវឌ្ឍន៍អាស៊ីក៏បានបន្តផ្តល់ការគាំទ្រសកម្មភាពRIAជាប្រភេទជំនួយបច្ចេកទេស TA8834-CAM ដើម្បីបន្តពង្រឹងសមត្ថភាពក្រុមការងារRIAនេះ រហូតដល់ខែមិថុនាឆ្នាំ២០១៩។

ដោយពិនិត្យឃើញថាកម្មវិធីនិងវិធីសាស្ត្រRIA បានផ្តល់ផលអត្ថប្រយោជន៍ច្រើនក្នុងការលើកកម្ពស់គុណភាពលិខិតបទដ្ឋានគតិយុត្ត រាជរដ្ឋាភិបាលបានចេញសេចក្តីសម្រេចលេខ១៣២ សសរ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបង្កើតក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត។ ចាប់តាំងពីពេលនោះមក នៅដើមឆ្នាំ២០១៧ ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត (ក.ប.ល.) របស់ ECOSOCC ត្រូវបានបង្កើតឡើងថ្មីដោយចេញពីឈ្មោះដើមថាក្រុមការងារអនុវត្តគម្រោងវាយតម្លៃលើផលប៉ពាល់នៃលិខិតបទដ្ឋានគតិយុត្ត(វ.ផ.ល.) ហៅកាត់ជាភាសាអង់គ្លេសថា ORIA។ ក.ប.ល. មានតួនាទីជាសេនាធិការឲ្យECOSOCC និងមានភារកិច្ចចំបងគឺបណ្តុះបណ្តាល ផ្សព្វផ្សាយ សម្របសម្រួល ផ្តល់យោបល់ដល់ក្រុមការងារRIA ក្រសួងស្ថាប័នក្នុងការអនុវត្តRIA។ ក្នុងឆ្នាំ២០១៧ដដែលមានក្រសួង ស្ថាប័នចំនួន៣ បានចូលរួមបន្ថែមទៀត គឺក្រសួងយុត្តិធម៌ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ និងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។ ដូច្នេះត្រឹមដើមឆ្នាំ២០១៧ រហូតដល់ខែមិថុនា ឆ្នាំ២០១៩ មានក្រុមការងារRIAក្រសួងចំនួន១៥ រដ្ឋលេខាធិការដ្ឋានចំនួន១ និងស្ថាប័នចំនួន២ ចូលរួមកម្មវិធីRIA ហើយជាទូទៅធនធានមនុស្សក្រុមការងារទាំងនោះល្មមគ្រប់គ្រាន់អាចអនុវត្តRIAបានឲ្យតែមានថវិកា និងការសម្រេចពីថ្នាក់ដឹកនាំក្រសួងសាមីនីមួយៗ។



ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា ដឹកនាំប្រជុំចង្អៀតជាមួយតំណាងទីស្តីការគណៈរដ្ឋមន្ត្រី និងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ និងក្រុមប្រឹក្សាអ្នកច្បាប់ ដើម្បីពិនិត្យលើសេចក្តីព្រាងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតក្រុមការងារវាយតម្លៃលើផលបះពាល់នៃលិខិតបទដ្ឋានគតិយុត្ត



## ២- ការងារនិងសកម្មភាពRIA

កម្មវិធីRIAនិងវិធីសាស្ត្រRIA មានគោលបំណងពង្រឹងប្រសិទ្ធភាព និងប្រសិទ្ធផលនៃបញ្ញត្តិកម្ម តាមរយៈការដាក់ឲ្យអនុវត្តនូវគោលការណ៍ប្រតិបត្តិល្អក្នុងនីតិវិធីរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្តនៅតាមក្រសួង ស្ថាប័ន ដោយយកវិធីសាស្ត្រRIAជាឧបករណ៍បច្ចេកទេសសម្រាប់ធ្វើការវាយតម្លៃ។

ក្នុងរយៈពេលជាង៧ឆ្នាំនៃការអនុវត្តគម្រោងនិងកម្មវិធីRIA ECOSOCCនិងក្រសួង ស្ថាប័នបានសហការគ្នាយ៉ាងសកម្ម ដើម្បីបំពេញការងារដ៏លំបាកនេះ ព្រោះការអនុវត្តតាមវិធីសាស្ត្រRIAនេះជាការផ្លាស់ប្តូរផ្នត់គំនិត(mindset) ពីទម្លាប់ធម្មតា ទៅទម្រង់បែបបទបច្ចេកទេស ដែលប្រទេសផ្សេងទៀតជាច្រើនបានប្រើប្រាស់យូរមកហើយ។ ម្យ៉ាងទៀតប្រទេសASEANមួយចំនួនបានអនុវត្តRIAចែងដោយច្បាប់មាននៅប្រទេសឥណ្ឌូនេស៊ី ឡាវ ហ្វីលីពីន ថៃ និងវៀតណាម ចំពោះប្រទេសម៉ាឡេស៊ីបានកំណត់ក្នុងគោលនយោបាលអភិវឌ្ឍន៍ជាតិហើយអនុវត្តបានយ៉ាងល្អ ដោយឡែកប្រទេសសឹង្ហបុរី មិនប្រើទម្រង់RIAចំទេ ប៉ុន្តែអនុវត្តលើបទប្បញ្ញត្តិឆ្លាតវៃ (Smart Regulation, pro-enterprises panel and zero in process) និងជាពិសេសមានការវិភាគបន្ទុកចំណាយនិងផលចំណេញច្បាស់លាស់ (Cost Benefit Analysist)។ ជាលទ្ធផលនៃកម្មវិធីត្រូវបានបែងចែកជា ៧ផ្នែកធំៗ គឺទី១. ការកសាងសមត្ថភាព ទី២. ការរៀបចំរបាយការណ៍RIA ទី៣. ការផ្សព្វផ្សាយ ទី៤. ការគ្រប់គ្រងនិងការត្រួតពិនិត្យគម្រោងនិងកម្មវិធីRIA ទី៥. ការសិក្សាពីការពិគ្រោះយោបល់ស្ទង់មតិលើការអនុវត្តកម្មវិធីRIA ទី៦. បញ្ហាប្រឈម និងទី៧. សេចក្តីសន្និដ្ឋាននិងទិសដៅការងារអនុវត្តបន្ត ដែលសង្ខេបដូចខាងក្រោម៖

### ការកសាងសមត្ថភាព

ការកសាងសមត្ថភាពត្រូវបានរៀបចំឡើងជាពីរចំណុច គឺទី១.ការបណ្តុះបណ្តាលក្នុងស្រុក និងទី២. ទស្សនកិច្ចសិក្សាដកបទពិសោធន៍នៅបរប្រទេស(រួមទាំងការចូលរួមសិក្ខា ព្រមទាំងចែករំលែកបទពិសោធន៍ក្នុងកិច្ចប្រជុំ ឬសិក្ខាសាលា ឬសន្និសិទ្ធអន្តរជាតិក្នុងបណ្តាប្រទេសASEANនិងOECDផងដែរ)។ ពេលចាប់ផ្តើមគម្រោងRIA ធនាគារអភិវឌ្ឍន៍អាស៊ីបានជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាអន្តរជាតិ ដែលមានទីប្រឹក្សាអន្តរជាតិ ចំនួន៣រូបមកធ្វើការបណ្តុះបណ្តាល និងហ្វឹកហាត់លើការរៀបចំរបាយការណ៍RIAរបស់ក្រសួង ស្ថាប័ន ហើយបន្តមកក្រុមការងារRIAរបស់ECOSOCC មានសមត្ថភាពនឹងទទួលបន្ទុកអាចធ្វើជាគ្រូបង្គោលក្នុងការងារបណ្តុះបណ្តាល និងផ្តល់យោបល់ដល់ក្រសួង ស្ថាប័នក្នុងការៀបចំរបាយការណ៍RIAដោយខ្លួនឯង នៅពេលទីប្រឹក្សាអន្តរជាតិ បានបញ្ចប់ភារកិច្ច និងបានចាកចេញនៅខែមីនា ឆ្នាំ២០១៣។

ការបណ្តុះបណ្តាលរួមមានធាតុទាំង៧នៃវិធីសាស្ត្រRIA និងការវិភាគបន្ទុកចំណាយ និងផលចំណេញ (CBA) បានចំនួន៣១លើកដែលមានអ្នកចូលរួមសរុបប្រមាណ ១១៣២ រូប។ ក្រៅពីការរៀបចំនិងផ្តល់ការបណ្តុះបណ្តាលដោយខ្លួនឯង ក្រុម RIA របស់ECOSOCCក៏បានរៀបចំចាត់ចែងឲ្យមានការបណ្តុះបណ្តាលរយៈពេលខ្លីនៅទីស្តីការគណរដ្ឋ-មន្ត្រី លើមុខវិជ្ជាការវិភាគបន្ទុកចំណាយ និងផលចំណេញឲ្យកាន់តែស៊ីជម្រៅ ដែលបង្រៀនដោយអ្នកជំនាញអន្តរជាតិដែលមានបទពិសោធអនុវត្តជាក់ស្តែង(resource person) មកពីប្រទេសអូស្ត្រាលី





ហើយក៏មានចុះកិច្ចសន្យាជាមួយ CamEd Business School ឲ្យបង្រៀនលើមុខវិជ្ជាការវិភាគបន្ទុកចំណាយ និង ផលចំណេញ និងគោការណ៍សេដ្ឋកិច្ច និងជាមួយសកលវិទ្យាល័យអាមេរិកកាំងភ្នំពេញ ឲ្យបណ្តុះបណ្តាល លើមុខវិជ្ជាបណ្តុះបណ្តាលគ្រូបង្គោល គោលនយោបាយសាធារណៈ ដែលជាមុខវិជ្ជាបំពេញបន្ថែមដើម្បី បង្កើនចំណេះដឹង ដោយមានមន្ត្រីចូលរួមក្នុងវគ្គនោះចំនួនសរុប ២៦៨រូប។








# បណ្តុំរូបភាពមួយចំនួនស្តីពីសកម្មភាពនៃវគ្គបណ្តុះបណ្តាលផ្សេងៗ




ដើម្បីពង្រឹងនិងពង្រីកចំណេះដឹង និងដកបទពិសោធនៃការអនុវត្តRIA ក.ប.ល. ក៏បានបញ្ជូនមន្ត្រីចំនួន ៨៨រូប មកពីក្រសួង ស្ថាប័ននិងក.ប.ល. ទៅរៀនសូត្រស្វែងយល់ពីចំណេះដឹង និងដកបទពិសោធនៅប្រទេសអូស្ត្រាលី អង់គ្លេស វៀតណាម និងកាណាដា ដែលជាប្រទេសអនុវត្តRIAបានជោគជ័យ។ ក្នុងឱកាសនោះ មន្ត្រីក្រុមការងារRIA បានជួបពិភាក្សានិងផ្លាស់ប្តូរយោបល់ជាមួយអ្នកប្រតិបត្តិRIAនៃក្រសួងស្ថាប័នជាច្រើនរបស់បណ្តាប្រទេសទាំងនោះ ដែលនាំឲ្យមន្ត្រីមានជំនឿលើអត្ថប្រយោជន៍នៃការការអនុវត្តRIA។




ថ្នាក់ដឹកនាំក្រុមRIAមួយចំនួនក៏បានទៅចូលរួមក្នុងវេទិកាប្រជុំនិងសិក្ខាសាលារបស់ ASEAN-OECD, ASEAN-New Zealand ស្តីពីបណ្តាញអ្នកប្រតិបត្តិល្អលិខិតបទដ្ឋានគតិយុត្ត ការអនុវត្តRIAព្រមទាំងកិច្ចសហប្រតិបត្តិការបទបញ្ញត្តិកម្មអន្តរជាតិ ព្រមទាំងសិក្ខាសាលាលើកទី៨របស់ OECD “Towards Better Regulation: New Approaches, New Challenges” និងកិច្ចប្រជុំស្តីពីការពិភាក្សាអំពីផលប៉ះពាល់៖ តួនាទីនៃក្របខ័ណ្ឌស្ថាប័នក្នុងគោលនយោបាយរៀបចំលិខិតបទដ្ឋានគតិយុត្ត “Measuring Regulatory Performance” ជាដើម ចំនួន៧លើកនៅប្រទេស Indonesia, Lao, China, Australia, Philippines and Malaysia ដើម្បីពង្រីកការយល់ដឹងជាសកល និងតាមដាននូវអ្វីដែលប្រទេសគេផ្សេងៗ បាននឹងកំពុងអនុវត្តយ៉ាងសកម្មដើម្បីពង្រឹងបញ្ញត្តិកម្មក្នុងការចូលរួមចំណែកលើការជំរុញភាពប្រកួតប្រជែងយ៉ាងមានប្រសិទ្ធភាព និងប្រសិទ្ធផល។















## ការរៀបចំរបាយការណ៍RIA




ចាប់ពីឆ្នាំ២០១១ ដល់ខែមិថុនា ឆ្នាំ២០១៩ ក.ប.ល. បានដឹកនាំសម្របសម្រួលកិច្ចប្រជុំពិភាក្សា និងផ្តល់យោបល់បានចំនួន ១១៤លើក លើសេចក្តីព្រាងរបាយការណ៍RIAចំនួន៦៥ ដែលរៀបចំដោយក្រុមការងារ RIAនៃក្រសួង ស្ថាប័ន ហើយបានបញ្ចប់របាយការណ៍វាយតម្លៃបឋមចំនួន ៥៥ (7MOC, 8MoME, 6MoE, 6MoT, 2MAFF, 3MoLVT, 14MoEYS, 1MPWT, 1MEF, 1MPTC, 3MoIH, 1MoJ, 1MND) និងរបាយការណ៍វាយតម្លៃពេញលេញ ចំនួន ៣ (2MoLVT,1MAFF) ហើយកំពុងបន្តរៀបចំរបាយការណ៍វាយតម្លៃបឋមចំនួន៦ (1MoC, 1MoME, 1MoAFF, 1MoLVT, 1MoH 1MoPWT) និងរបាយការណ៍វាយតម្លៃពេញលេញចំនួន១ (MoEYS)[១]។

*ក.ស.វ. - ក្រុម RIA*

(១) អត្ថបទនេះមានតនៅលេខក្រោយទៀត។

## សកម្មភាព ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា

| ល.រ | កាលបរិច្ឆេទ | សកម្មភាពក្នុងខែមិថុនាឆ្នាំ២០១៩ |
|---|---|---|
| ១ | ០១/០៦/១៩ **ម៉ោង០៨:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីមីទ្ទិញអបអរសាទរខួបលើកទី៧០ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី១៨ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៩ ក្រោមប្រធានបទ " លើកកម្ពស់សិទ្ធិកុមារតាមរយៈការលុបបំបាត់អំពើហិង្សាលើកុមារគ្រប់រូបភាព " ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម នាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ២ | ០៣/០៦/១៩ **ម៉ោង០៧:២០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិត សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ៣ | ០៤/០៦/១៩ **ម៉ោង០៨:៣០នាទី** | ដឹកនាំក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមេសា ឆ្នាំ២០១៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៥/០៦/១៩ **ម៉ោង០៩:០០នាទី** | ដឹកនាំអង្គប្រជុំ ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ)២០១៩-២០២៣។<br>២- សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត។<br>៣- បញ្ហាផ្សេងៗ។ ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៥/០៦/១៩ **ម៉ោង១៥:០០នាទី** | ដឹកនាំក្នុងកិច្ចប្រជុំ ដើម្បីរៀបចំសមាសភាព និងការងាររបស់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានស្រុកព្រៃកប្បាស នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ០៦/០៦/១៩ **ម៉ោង០៩:០០នាទី** | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយសម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ) ២០១៩-២០២៣។<br>២-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត<br>៣-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| | | |
|---|---|---|
| ៧ | ០៧/០៦/១៩<br>ម៉ោង០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ) ២០១៩-២០២៣។<br>២-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត<br>៣-បញ្ហាផ្សេងៗ។ នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៨ | ០៧/០៦/១៩<br>ម៉ោង១៥:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម លោកជំទាវ ទីប្រឹក្សាបច្ចេកទេស នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | ១៣/០៦/១៩<br>ម៉ោង០៩:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រកាសចូលកាន់តំណែងក្រុមប្រឹក្សាខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តតាកែវ នៅសាលប្រជុំសាលាខេត្តតាកែវ។ |
| ១០ | ២៨/០៦/១៩<br>ម៉ោង០៨:០០នាទី | ចូលរួមជាគណៈអធិបតី ក្នុងពិធីរំឭកខួបអនុស្សាវរីយ៍លើកទី៦៨ ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា (២៨ មិថុនា ១៩៥១ - ២៨ មិថុនា ២០១៩) នៅទីស្នាក់ការគណបក្សស្រុកព្រៃកប្បាស។ |
| **ល.រ** | **កាលបរិច្ឆេទ** | **សកម្មភាពក្នុងខែកក្កដាឆ្នាំ២០១៩** |
| ១ | ០២/០៧/១៩<br>ម៉ោង០៨:៣០នាទី | ដឹកនាំក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា ឆ្នាំ២០១៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី (អគារថ្មីខាងត្បូង សាល៧-០៨ ជាន់ទី៧)។ |
| ២ | ០៣/០៧/១៩<br>ម៉ោង០៩:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា ឆ្នាំ២០១៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី (បន្ទប់១៣២)។ |
| ៣ | ០៤/០៧/១៩<br>ម៉ោង១៤:៣០នាទី | រៀបចំកិច្ចការងារ និងឯកសារ នៅស្ថានទូតបារាំងប្រចាំនៅកម្ពុជា។ |
| ៤ | ២៩/០៧/១៩<br>ម៉ោង០៨:១៥នាទី | ជួបប្រជុំដើម្បីពិភាក្សាការងារជាមួយ ឯកឧត្តម **គី តិច** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ៣០/០៧/១៩<br>ម៉ោង០៩:០០នាទី | ជួបប្រជុំដើម្បីពិភាក្សាការងារជាមួយ ឯកឧត្តម **គី តិច** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ៣១/០៧/១៩<br>ម៉ោង០៩:៣០នាទី | ដឹកនាំអង្គប្រជុំដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម<br>២-សេចក្តីព្រាងគោលនយោបាយជាតិភាសាខ្មែរ<br>៣-បញ្ហាផ្សេងៗ ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយ ឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី (បន្ទប់១៣២)។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាពក្នុងខែសីហាឆ្នាំ២០១៩ |
|---|---|---|
| ១ | ០១/០៨/១៩<br>ម៉ោង០៩:០០នាទី | ចូលរួមជាសមាជិកក្នុងកិច្ចត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម<br>២-សេចក្តីព្រាងគោលនយោបាយជាតិភាសាខ្មែរ<br>៣-បញ្ហាផ្សេងៗ:កិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងអង្គការហាមឃាត់អាវុធគីមី ស្តីពីបុព្វសិទ្ធិនិងអភ័យឯកសិទ្ធរបស់អង្គការ OPCW។<br>នៅទីស្តីការគណៈ រដ្ឋមន្ត្រី (បន្ទប់៦០៩)។ |
| ២ | ០២/០៨/១៩<br>ម៉ោង០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គ-មហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម<br>២-សេចក្តីព្រាងគោលនយោបាយជាតិភាសាខ្មែរ<br>៣-បញ្ហាផ្សេងៗ: កិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងអង្គការហាមឃាត់អាវុធគីមី ស្តីពីបុព្វសិទ្ធិនិងអភ័យឯកសិទ្ធរបស់អង្គការOPCW។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី (វិមានសន្តិភាព)។ |
| ៣ | ០៥/០៨/១៩<br>ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រ និងវិញ្ញាបនបត្រជូនដល់និស្សិត និងសិក្ខាម នៃបណ្ឌិតសភានគរបាលកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅបណ្ឌិតសភានគរបាលកម្ពុជា ស្រុកកៀនស្វាយ ខេត្តកណ្តាល។ |
| ៤ | ០៦/០៨/១៩<br>ម៉ោង០៩:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **គី តិច** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៧/០៨/១៩<br>ម៉ោង១៤:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកវេទិកាធុរកិច្ចកម្ពុជា-ស្រីលង្កា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **ម៉ៃទ្រីប៉ាឡា ស៊ីរីសេនា** ប្រធានាធិបតី នៃសាធារណរដ្ឋប្រជាធិបតេយ្យសង្គមនិយមស្រីលង្កា នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូកេត្រា។ |
| ៦ | ០៩/០៨/១៩<br>ម៉ោង១៥:៣០នាទី | ចូលរួមក្នុងកិច្ចប្រជុំ ក្រោមអធិបតីភាព ឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ប្រធានគណៈកម្មាធិការគណបក្សទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិភាក្សាលើ៖<br>១-ការកែសម្រួលនិងបំពេញបន្ថែមសមាសភាពគណៈអចិន្ត្រៃយ៍ នៃគណៈកម្មាធិការគណបក្សទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន០១រូប។<br>២-ការកែសម្រួលនិងបំពេញបន្ថែមសមាសភាពគណៈកម្មាធិការគណបក្សទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន០៣រូប។ នៅសាលD ជាន់ទី៣ (អគារមិត្តភាព)។ |

| | | |
|---|---|---|
| ៧ | **១២/០៨/១៩**<br>**ម៉ោង១០:០០នាទី** | ជួបប្រជុំដើម្បីពិភាក្សាការងារជាមួយ ឯកឧត្តម **ឈីវ យីស៊ាង** រដ្ឋលេខាធិការ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ នៅទីស្តីការក្រសួងការបរទេស និងសហ-ប្រតិបត្តិការអន្តរជាតិ។ |
| ៨ | **២២/០៨/១៩**<br>**ម៉ោង០៧:៣០នាទី** | ចូលរួមប្រជុំគណៈកម្មាធិការកណ្តាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា នៅសាលស៊ីធីហលនៃមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ៩ | **២៧/០៨/១៩**<br>**ម៉ោង០៩:៣០នាទី** | ដឹកនាំក្នុងកិច្ចប្រជុំគណៈប្រតិបត្តិរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ប្រចាំខែសីហា ឆ្នាំ២០១៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី (បន្ទប់១៣២)។ |
| ១០ | **២៨/០៨/១៩**<br>**ម៉ោង០៩:៣០នាទី** | ដឹកនាំអង្គប្រជុំ ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីសំណង់<br>២-សេចក្តីព្រាងឯកសារកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០២០-២០២២<br>៣-សេចក្តីព្រាងរបាយការណ៍ស្វ័យវាយតម្លៃ ស្តីពីការត្រួតពិនិត្យឡើងវិញ នៃការអនុវត្តអនុសញ្ញាអង្គការសហប្រជាតិប្រឆាំងអំពើពុករលួយ (អ៊ុនកាក់, UNCAC)<br>៤-បញ្ហាផ្សេងៗ: ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយ ឯកឧត្តមកិត្តិនីតិ-កោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី (បន្ទប់១៣២)។ |
| ១១ | **២៩/០៨/១៩**<br>**ម៉ោង០៩:០០នាទី** | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយសម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីសំណង់<br>២-សេចក្តីព្រាងឯកសារកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០២០-២០២២<br>៣-សេចក្តីព្រាងរបាយការណ៍ស្វ័យវាយតម្លៃ ស្តីពីការត្រួតពិនិត្យឡើងវិញ នៃការអនុវត្តអនុសញ្ញាអង្គការសហប្រជាតិប្រឆាំងអំពើពុករលួយ (អ៊ុនកាក់, UNCAC)<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី (បន្ទប់៦០៩)។ |
| ១២ | **៣០/០៨/១៩**<br>**ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គ-មហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីសំណង់<br>២-សេចក្តីព្រាងឯកសារកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០២០-២០២២<br>៣-សេចក្តីព្រាងរបាយការណ៍ស្វ័យវាយតម្លៃ ស្តីពីការត្រួតពិនិត្យឡើងវិញ នៃការអនុវត្តអនុសញ្ញាអង្គការសហប្រជាតិប្រឆាំងអំពើពុករលួយ (អ៊ុនកាក់,UNCAC)<br>៤- បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី (វិមានសន្តិភាព)។ |

## ពន្យល់ពាក្យ

ហេតុ (ន.)៖ គឺជាការឬដំណើរប្រព្រឹត្តទៅ ការណ៍ ទំនង ដើមទង ដើមចម។

ហេតុ ចែកចេញជា៖

ក. ហេតុនៃសុខមាន ៤យ៉ាង៖

១. អត្ថិសុខ = សុខព្រោះមានសម្បត្តិ

២. ភោគសុខ = សុខព្រោះចេះប្រើប្រាស់សម្បត្តិ

៣. អនណសុខ = សុខព្រោះគ្មានបំណុល

៤. អនវជ្ជសុខ = សុខព្រោះធ្វើល្អ

ខ. ហេតុនៃឃាតកម្មមាន ៨យ៉ាង៖

១. រាគវសេន = សម្លាប់ដោយសាររាគ

២. ទោសវសេន = សម្លាប់ដោយសារទោស

៣. មោហវសេន = សម្លាប់ដោយសារមោហា

៤. មានវសេន = សម្លាប់ដោយសារមានៈ

៥. លោភវសេន = សម្លាប់ដោយសារលោភៈ

៦. ជីវិតក្ខាយវសេន = សម្លាប់ដោយសារចិញ្ចឹមជីវិត

៧. អញ្ញាណវសេន = សម្លាប់ដោយសារមិនដឹង

៨. វិនយវសេន = សម្លាប់ដោយសារវិន័យ

គ. ហេតុនៃការឲ្យទានមាន ៨យ៉ាង៖

១. ឲ្យទានព្រោះស្រឡាញ់គ្នា

២. ឲ្យទានព្រោះខឹង

៣. ឲ្យទានព្រោះវង្វេង

៤. ឲ្យទានព្រោះខ្លាច

៥. ឲ្យទានព្រោះធ្លាប់

៦. ឲ្យទានព្រោះសប្បាយ

៧. ឲ្យទានព្រោះចង់ទៅឋានសួគ៌ ឋាននិព្វាន

៨. ឲ្យទានព្រោះចង់សម្អាតចិត្ត

ឃ. ហេតុនៃការស្ថាបនាប្រាសាទច្រើនសន្ធឹកសន្ធាប់មាន ៦យ៉ាង៖

១.បុព្វហេតុសាសនា- ការកាន់សាសនាខុសគ្នា បានធ្វើឲ្យស្តេចខ្មែរពុំព្រមគោរពបូជាប្រាសាទដដែលៗ ហើយក៏បានចាត់ចែងឲ្យគេស្ថាបនាប្រាសាទដទៃទៀត តម្រូវតាមបំណងនិង ជំនឿរបស់ព្រះអង្គ។

២.បុព្វហេតុកិត្តិយស- ការស្ថាបនាប្រាសាទជាសក្ខីភាពបញ្ជាក់នូវកិត្តិយសរបស់ព្រះមហាក្សត្រក្នុងការបង្ហាញនូវថ្វីព្រះហស្ត ការប៉ិនប្រសប់ ទេពកោសល្យ និងប្រាជ្ញាវាងវៃរបស់ព្រះអង្គ។ ការស្ថាបនាប្រាសាទប្រកបដោយក្បាច់ចម្លាក់ល្អប្រណីត ផ្ទៃក្រឡាធំ ថ្មស្ថិត រាងសមគយគន់ទីល្អគ្រប់ទិសគ្មានទាស់ ខ្ពស់ត្រដែតទៅលើនភាល័យ ជាងប្រាសាទដទៃទៀត ជាការបញ្ជាក់នូវកិត្តិយសរបស់ព្រះមហាក្សត្រ អ្នកស្ថាបនាព្រមទាំងផ្សាយនូវបារមីរបស់ព្រះអង្គដល់ប្រជារាស្ត្រទៀតផង។

៣.បុព្វហេតុទម្លាប់- ការស្ថាបនាប្រាសាទក៏ជាទម្លាប់មួយដែរ។ នៅពេលឡើងសោយរាជ្យម្តងៗ ស្តេចខ្មែរទម្លាប់ឲ្យស្ថាបត្យករជំនាញៗ សង់ប្រាសាទទុកជាកេរ្តិ៍ដំណែលនៃរជ្ជកាលរបស់ព្រះអង្គ។

៤.បុព្វហេតុប្រវត្តិសាស្ត្រ- ការស្ថាបនាប្រាសាទប្លែកៗគ្នា ជាគោលបំណងមួយទៀតរបស់ស្តេចខ្មែរ ដើម្បីឲ្យកិត្តិនាមរបស់ព្រះអង្គល្បីសុសសាយក្នុងប្រវត្តិសាស្ត្រ។

៥.បុព្វហេតុសង្គ្រាម- ការស្ថាបនាប្រាសាទឲ្យកាន់តែធំ មាំ ទូលាយ មានច្រកចេញចូលខ្វាត់ខ្វែងជាមធ្យោបាយដើម្បីទប់ទល់នឹងខ្មាំងសត្រូវ មានចាមនិងសៀមជាដើម។ នៅប្រាសាទអង្គរធំ គេសង្កេតឃើញមានរូងក្នុងដី ជាផ្លូវសម្ងាត់សម្រាប់ព្រះមហាក្សត្រ នៅពេលដែលសត្រូវចូលមកដល់ភ្លាមដោយមិនបានប្រុងប្រយ័ត្នមុន ឬទប់ទល់នឹងសត្រូវពុំរួច។

៦.បុព្វហេតុផ្លាស់ប្តូរទីក្រុង- ការផ្លាស់ប្តូរទីក្រុងក៏តម្រូវឲ្យព្រះមហាក្សត្របញ្ជាឲ្យរៀបចំស្ថាបនាប្រាសាទវាំងថ្មីជាដរាប។ ឧទាហរណ៍:

- នៅលើភ្នំគូលែន
- នៅសៀមរាប
- នៅឧត្តុង្គ
- នៅរលួស
- នៅលង្វែក
- នៅភ្នំពេញ

ង. ហេតុដែលស្ថាបនាអង្គរវត្តបែរមុខទៅទិសខាងលិច មាន ៧យ៉ាង៖

១.អង្គរវត្តជាផ្នូររបស់ព្រះបាទសូរ្យវរ្ម័នទី២ (ក្បាលទៅទិសខាងលិច)

២.អង្គរវត្តជាមន្ទីរសង្កេតមើលផ្កាយ (ពេលថ្ងៃលិច)

៣.អង្គរវត្តនៅជិតបង្កើយនឹងស្ទឹងសៀមរាបពីទិសខាងកើត ពុំអាចធ្វើផ្លូវបានល្អ និងគ្មានកន្លែងធ្វើបុណ្យទានផ្សេងៗ។

៤.អង្គរវត្តបើសង់បែរមុខទៅទិសខាងកើត វាហាក់ដូចជាហុចគូថទៅលើប្រាសាទ សំខាន់ៗឯទៀតនៅតំបន់អង្គរធំ។

៥.អង្គរវត្តសង់បែរមុខទៅទិសខាងលិច ដោយផ្លូវតភ្ជាប់អង្គរធំមកអង្គរវត្តត្រូវចូលពីទិសខាងលិច ព្រោះបណ្តាប្រាសាទនៅអង្គរធំកសាងមុនអង្គរវត្ត ងាយស្រួលទំនាក់ទំនងរវាងបណ្តាប្រាសាទទាំងឡាយក្នុងក្រុងអង្គរ។

៦.អង្គរវត្តសង់បែរមុខទៅទិសខាងលិច គឺបែរសំដៅទៅលើវិសាលភាពដ៏ធំទូលាយនៃទឹកដីខ្មែរនៅទិសខាងលិចមាន៖ សុខោទ័យ អាយុធ្យា នគររាជសីមា បស្ចិមបុរី ចន្ទបូរី ធនបុរី បឹងកក់ លពបុរី គោត្របូរ(ភីម៉ាយ) រយ៉ង នាងរង ល្វោ សូរិន ស្រះកែវ ត្រាត ស៊ីសាកេត...។

៧.អង្គរវត្តបែរមុខទៅទិសខាងលិច គឺផ្តល់ភាពអនុគ្រោះដល់ការភ្នំពលទ័ព ក្រោមព្រះរាជបញ្ជាការផ្ទាល់របស់ព្រះមហាក្សត្រ ដើម្បីលើកទឹកចិត្តកងទ័ពមុនពេលចេញប្រយុទ្ធជាមួយសត្រូវ ដោយសារមានទីធ្លាធំទូលាយ៕

# កម្លាំងអរិយធម៌ឋិតនៅលើអ្វី?

អរិយធម៌នៃប្រជាជាតិនីមួយៗអាចចម្រើនរុងរឿង ហើយអាចចុះដុនដាបទៅវិញ ឋិតនៅលើកម្លាំងពីរជាមូលដ្ឋាន៖

ក- កម្លាំងអរិយធម៌ស្ថិតនៅលើវប្បធម៌ :

១- វប្បធម៌ភ្ញាស់គំនិត៖

- អ្នកអក្សរសាស្ត្រ
- អ្នកវិទ្យាសាស្ត្រ
- អ្នកអប់រំ

២- គំនិតជាអំណាចអាច៖

- ប្តូរទម្រង់សង្គម
- បង្កើនកម្រិតជីវភាព
- បង្កើនចរិយាឲ្យថ្លៃថ្នូរ
- បង្កើនច្បាប់គ្រប់គ្រងត្រឹមត្រូវ បានសេចក្តីថាផ្តល់សុខៈដល់សង្គម

៣- ដូចនេះវប្បធម៌ជាកម្លាំងធ្វើឲ្យអរិយធម៌ជឿនលឿន។

ខ- កម្លាំងអរិយធម៌ឋិតនៅលើសង្គមធម៌ :

១- សង្គមធម៌សម្គាល់ការលូតលាស់ផ្នែកសម្ភារៈសង្គម៖

- ប្រដាប់ប្រើប្រាស់
- បច្ចេកទេសបង្កើនផល
- វិធីរៀបចំសង្គម សេដ្ឋកិច្ច នយោបាយ សង្គមកិច្ច

២- សង្គមធម៌អាចប្តូរជីវភាព៖

- ជីវិតប្តូរគំនិតទស្សនៈមនុស្ស
- ប្តូរនយោបាយ ប្តូរសេដ្ឋកិច្ច ប្តូរតំបន់បង្កើតផល ទស្សនៈប្តូរជំនឿ មនុស្សប្តូរទៅតាមនោះដែរ
- សង្គមលូតលាស់ អបិយជំនឿថយចុះ

៣- ដូចនេះអរិយធម៌ទៅមុខ ឬថយក្រោយស្រេចតែសង្គមធម៌។

តាមពិតអរិយធម៌ទៅមុខ ឬថយចុះលឿន ឬមិនលឿន ពុំមែនមកពីកម្លាំងវប្បធម៌ ឬកម្លាំងសង្គមធម៌តែឯកឯងទេ គឺមកពីកម្លាំងពីររួមគ្នា៖

- អរិយធម៌ជឿនលឿនកាលណាវប្បធម៌បោះជំហានទៅមុខត្រូវចង្វាក់គ្នានឹងសង្គមធម៌។ បានសេចក្តីថា ត្រូវរៀបចំគ្រប់មែកធាងឲ្យប្រទាក់ប្រទងគ្នាជាចង្វាក់។

- វប្បធម៌លឿនតែម្នាក់ឯង សង្គមធម៌ទន់ខ្សោយ អរិយធម៌ស្រុតចុះ។

អរិយធម៌អង្គរដែលឡើងដល់កំពូលពីសតវត្សទី៩ដល់ទី១៣ ដោយសារគ្រឹះវប្បធម៌ "មានលទ្ធិទេវរាជា" និងគ្រឹះសង្គមធម៌ សេដ្ឋកិច្ច សង្គមកិច្ច( បារាយតម្កល់ទឹក ប្រឡាយទឹក មន្ទីរពេទ្យ សាលាធទាន ) ដើរ-

ត្រូវចង្វាក់គ្នា។ ក្រោយសតវត្សទី១៣ អរិយធម៌អង្គរដួលរលំដោយសារអ្នកដឹកនាំរៀបតែផ្នែកវប្បធម៌ "សាង-ប្រាសាទដើម្បីសក្ការៈបូជា ដើម្បីកិត្តិយសផ្ទាល់" ព្រងើយកន្តើយនឹងផ្នែកសង្គមធម៌ បណ្ដាលឲ្យសេដ្ឋកិច្ចធ្លាក់ចុះ សង្គមកិច្ចធ្លាក់ប្រេះឆា។

សង្គមធម៌ជឿនលឿនតែម្នាក់ឯង វប្បធម៌តាមមិនទាន់ អរិយធម៌ធ្លាក់ចុះមួយរំពេច។ ឧទាហរណ៍-សម័យកាលខ្លះនៃសង្គមកម្ពុជា វប្បធម៌តាមមិនទាន់សង្គមធម៌ៈ

- កសាងនិម្មាបនកម្មសង្គមរីកដូចផ្សិតតែខ្វះធនធានមនុស្សមានសមត្ថភាព ខ្វះសម្ភារៈ បរិក្ខាសង្ហារណៈ សម្បូរសាលាតែគ្រូមានតិចតួច ខ្វះវិជ្ជាគរុកោសល្យ កម្មវិធីសិក្សាបែបផ្សងព្រេង
- សុខភាពប្រជាជននៅផុយស្រួយ ខ្វះថ្នាំ ខ្វះគ្រូពេទ្យជំនាញ
- បង្អួតរូបភាពជាងគិតពីគុណភាព ផ្ទះខ្ទមរបងថ្ម ខ្លួនក្រចាយធំ
- នាំគ្នាអភិវឌ្ឍ ដោយមិនបានភ្ញាស់គំនិតអភិវឌ្ឍ ការអភិវឌ្ឍនោះក៏វសាត់គ្មានទិសដៅ ពង្រីកសង្គមធម៌មិនបានពង្រីកវប្បធម៌ ធ្វើឲ្យគ្រឹះទាំងពីររឹងមិនស្មើគ្នា បណ្ដាលឲ្យអរិយធម៌ឃ្លេងឃ្លោង។

ដូចនេះអរិយធម៌កកើតវិវត្តលូតលាស់ឬលិចលង់ គឺដោយសារទំនាក់ទំនងរវាងគ្រឹះទាំងពីរ កម្លាំងរួមរបស់វប្បធម៌និងសង្គមធម៌នេះឯង៕

*អត្ថាធិប្បាយអរិយធម៌ខ្មែរ - បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង*

**<u>គំនិតគួរចងចាំ</u>**

| | |
|---|---|
| អក្សរ | សារសព្ទប្រាប់រឿងពិត |
| រលត់ | ជីវិតចោលកូនខ្មែរ |
| ជាតិ | បានអ្វីសាងវប្បធម៌ដែរ |
| រលាយ | ជាតិខ្មែរព្រោះខ្មែរយើង។ |

សូនកំណាព្យ - បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង

## ស្ទៅចិញ្ចៀន (បទពាក្យ៩)

ស្ទៅចិញ្ចៀនរៀនដុះផុងក្នុងវារី
នៅសល់ពីទីទឹកស្មានបានពីរផ្ទាប់
ខ្យល់បក់បោកខោកឥតស្រាកងាករញោប់
នៅមិនងាប់ជាប់រហូតលូតឡើងបាន។
ជាតិបណ្ឌិតពិតពិរោះឈ្មោះឥតអាក់
មានឧបសគ្គស្ទាក់រាំងទាំងប៉ុន្មាន
ប្រឹងរុករានឈានឥតខ្សោយដោយក្លាហាន
ត្រាតែប្រាណបានរួចទុក្ខសុខដូចស្ទៅ។

*ព្រះឥន្ទមុនី - សេខ នាង*

## ច្បាប់ពាក្យចាស់ (បទព្រហ្មគីតិ)

ពាក្យចាស់ពាក្យពីព្រេង
ទោសខ្លួនឯងមើលពុំយល់
ទោសគេតូចសោតសស់
រមិលយល់ប៉ុនទាំងភ្នំ។
ចូលព្រៃសត្វសាហាវ
រកអំពាវគ្នាមកជុំ
ដល់បានស្រុកទឹកឃ្មុំ
ពួនក្នុងផ្ទះស៊ីម្នាក់ឯង។
បានហើយចង់បានទៀត
ផ្លៀតហើយផ្លៀតពុំគិតឈ្វេង
មើលយល់តែម្នាក់ឯង
មិនយល់គេឯទៀតផង។
នឹងស៊ីចង់ពិសារ
ខ្ជិលទំពារឲ្យម៉ដ្ឋហ្មង
យល់នាមថាជាមង
យល់ឯជងថាជាគួយ។
យល់តាថាជីដូន
យល់ឯកូនថាជាក្មួយ
យល់ពីរថាជាមួយ
យល់ឯព្រួយថាជាសុខ។
យល់ទោសថាជាគុណ
យល់ឯបុណ្យថានរក
យល់ល្អថាអាក្រក់
យល់លាមកថាជាផ្កា។

*សម្តេចព្រះសុគន្ធមានបុណ្យ ជិម*

## ភូមិខ្ញុំ (បទពាក្យ៧)

ទឹកដីនិងមេឃមួយដុំនេះ
កំណើតខ្ញុំចេះដឹងសេចក្តី
ទាំងរុក្ខជាតិឬបក្សី
ក៏ខ្ញុំបេតីមេត្រីគ្រប់។
បើខ្ញុំចាប់ជាតិជាដើមផ្កា
ប្រាថ្នាមកដុះនៅនាភព
នេះហើយសាយក្លិនក្រអូបឈ្ងប់
ទាំងថ្ងៃទាំងយប់ឥតឃ្លាតឃ្លា។
បើខ្ញុំជាឃ្មុំខ្ញុំហើរមក
ទីនេះស្វែងរកឈើនានា
ធ្វើបង្គងក្រេបរស់មាលា
បានជាក្បាលទឹកក្រមួនផង។
បើជាបក្សីបក្សាស្មោះ
សំឡេងពិរោះនោះបំណង
មកយំបន្លឺសព្ទសាសង
រំពងគឹកកងឲ្យគេស្តាប់។
ហេតុអីក៏ខ្ញុំស្រឡាញ់ម្ល៉េះ
តំបន់នេះអេះនោះខ្ញុំប្រាប់
ថាទីនេះហើយល្អចំណាប់
ជម្រាបសារសព្វគឺភូមិខ្ញុំ៕

*សួនកំណាព្យ - បណ្ឌិតសាស្ត្រាចារ្យ - អ៊ីវ ថុង*

## ទិះភ្លាត់

ថ្ងៃមួយប្រធានសហករណ៍មួយក្នុងស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដើរទៅមើលការដ្ឋានទំនប់ទឹកអំពែភ្នំ ក៏បានជួប អ៊ុំកុយ និង អ៊ុំផន កំពុងវេញខ្សែគោនៅក្រោមដើមពង្រ។ អ៊ុំទាំងពីរជាអតីតអធិការ អធិការរង នៃ អធិការដ្ឋានបឋមសិក្សាខេត្តកំពង់ស្ពឺ។

ប្រធានសហករណ៍សួរទៅអ៊ុំកុយថា៖

- មិត្តកុយឯងធ្វើអីដែរពីសង្គម?

អ៊ុំកុយឆ្លើយយ៉ាងសុភាពថា៖

- បាទ! សមមិត្តប្រធាន ធ្វើអធិការ...

គាប់ជួនពេលនោះ អ៊ុំផនលើកខ្សែគ្រវាសឡើង អ៊ុំកុយភ្ញាក់ដាច់សម្ដីត្រឹមហ្នឹង។

ប្រធានសហករណ៍សួរទៅអ៊ុំកុយបន្តថា៖

- នៅវត្តណា?

អ៊ុំកុយងើបមុខមើលអ៊ុំផន រួចឆ្លើយថា៖

- វត្តគ្រួស!

ប្រធានសហករណ៍ងាកមកសួរអ៊ុំផនវិញម្ដងថា៖

- ចុះមិត្តផនឯងវិញធ្វើអីដែរ?

អ៊ុំផនប្រញាប់ឆ្លើយថា៖

- បាទ! គ្រូសូត្រស្ដាំនៅវត្តជាមួយគ្នា។

ប្រធានសហករណ៍លាន់មាត់ថា៖

- យ៉ាស់! សុទ្ធសឹងតែជាពួកជិះជាន់កម្លាំងពលកម្មគេ!

ថាហើយក៏ដើរបន្តទៅមុខទៀតទៅ។ អ៊ុំកុយក៏ពោលទៅកាន់អ៊ុំផនថា៖

- បើកុំតែបានផនឯងលើកខ្សែគ្រវាសទាន់ កុំអីគ្នាថែមបឋមសិក្សាបាត់។

អ៊ុំផនគ្រញ៉ែងខ្លួន រួចឧទានឡើងថា៖

- វិះភ្លាត់ កុំអីឆ្អសឹង!

*អក្សរសិល្ប៍ប្រជាប្រិយខ្មែរ - បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង*

# ចុមបាត់ញើសអស់!

ថ្ងៃមួយលោកសេដ្ឋីមោកដើរត្រឡប់មកពីទារបំណុលគេវិញកណ្តាលថ្ងៃចែស ចូលដល់ក្នុងផ្ទះក៏ស្រែកហៅស្រីបម្រើឲ្យយកទឹកមួយផ្តិលមកជូន ហើយលោកឧទានខ្លាំងៗថា៖

អាបាវ! យកផ្លិតមកបក់ឲ្យអញ

នាយបាវឆ្លើយយ៉ាងរួសរាន់ថា៖

- ប្របាទទាន!

ថាហើយក៏ដើរចូលទៅអង្គុយបត់ជើងក្បែរកៅអីវែងទាំងដៃកាន់ផ្លិតបក់ឲ្យញាប់ស្មេរ។

លោកសេដ្ឋីលាន់មាត់ថា៖

- ហ៊ា! ក្តៅណាស់ ញើសជោកខ្លួនតែម្តង

មួយសន្ទុះក្រោយមក លោកសេដ្ឋីបើកភ្នែកធំៗ រួចសម្លឹងមុខអាបាវទាំងពោលថា៖

- ចុម! បាត់ញើសទៅណាអស់ទៅអាបាវ?

នាយបាវឆ្លើយទាំងដង្ហក់ថា៖

- ប្របាទទាន! វារត់មកនៅពេញខ្លួនខ្ញុំឯណេះ

- សេដ្ឋីមោកៈ ?!?!។

*អក្សរសិល្ប៍ប្រជាប្រិយខ្មែរ - បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង*

**គតិបណ្ឌិត**

" ឃើញគេថ្កុំថ្កើង កុំចចើងធ្វើតាម ហួសមាឌខ្លួន
ប៉ុន្តែមិនត្រូវបន្ធូរបន្ថយព្យាយាមឡើយ "

សម្តេចព្រះមហាសង្ឃរាជា **ជួន ណាត ជោតញ្ញាណោ**

# ដុល្លារូបនីយកម្មនៅកម្ពុជា

ដោយលោកជំទាវ គាល់ ណៃអ៊ីម

## ១. សេចក្តីផ្តើម

នៅក្នុងរបបខ្មែរក្រហម ប្រព័ន្ធហិរញ្ញវត្ថុត្រូវបានបំបាត់ចោលទាំងស្រុង ដោយពុំមានការប្រើប្រាស់រូបិយវត្ថុ ពុំមានធនាគារនិងពុំមានទីផ្សារលក់ដូរអ្វីឡើយ។ ប្រព័ន្ធសេដ្ឋកិច្ចនិងប្រព័ន្ធហិរញ្ញវត្ថុត្រូវបានបំផ្លាញទាំងស្រុងដល់ឬសគល់ ជាហេតុនាំឲ្យប្រជាជនបាត់បង់អស់នូវជំនឿទុកចិត្តមកលើប្រាក់រៀល និងប្រព័ន្ធហិរញ្ញវត្ថុ។ នៅពេលនោះ ប្រជាជនធ្លាក់ខ្លួនក្រតោកយ៉ាកមិនមានមុខរបរមិនមានប្រាក់កាសសម្រាប់ចាយវាយក្នុងជីវភាពប្រចាំថ្ងៃ។

បន្ទាប់ពីថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ ប្រជាជនកម្ពុជា បានចាប់ផ្តើមបន្លាស់ទីពីជនបទដាច់ស្រយាលមករស់នៅទីប្រជុំជនវិញ ហើយមុខរបរលក់ដូរតូចតាចសម្រាប់បម្រើឲ្យជីវភាពរស់នៅប្រចាំថ្ងៃក៏កើតមានឡើង។ ការលក់ដូរទាំងនោះភាគច្រើនត្រូវបានទូទាត់ដោយអង្ករ ឬដោយមាសដែលជាគ្រឿងអលង្ការទៅតាមលទ្ធភាពដែលប្រជាជនមាន។ លើសពីនេះក៏មានការប្រើប្រាស់ប្រាក់បាតនៅតាមជាយដែនកម្ពុជា-ថៃ និងប្រាក់ដុងវៀតណាមនៅតាមជាយដែនកម្ពុជា-វៀតណាម។ ចាប់ពីពេលនោះមក ប្រាក់រៀលត្រូវបានបោះពុម្ពផ្សាយសម្រាប់ប្រើប្រាស់ជារូបិយវត្ថុជាតិស្របច្បាប់។

## ២. ប្រវត្តិនៃដុល្លារូបនីយកម្មនៅកម្ពុជា

ដុល្លារូបនីយកម្ម សំដៅដល់សេដ្ឋកិច្ចដែលយកប្រាក់រូបិយបណ្ណបរទេស (ប្រាក់ដុល្លារអាមេរិក ប្រាក់អឺរ៉ូ។ល។) ប្រើប្រាស់ជំនួសឲ្យប្រាក់រូបិយវត្ថុរបស់ខ្លួន ឬប្រើប្រាស់ទន្ទឹមនឹងរូបិយវត្ថុរបស់ខ្លួន។ ប្រទេសដែលប្រកាន់យករបបរូបិយវត្ថុដូចខាងលើនេះ គឺភាគច្រើនជាប្រទេសដែលមានសេដ្ឋកិច្ចតូច និងអត្រាអតិផរណាមានកម្រិតខ្ពស់មិនអាចគ្រប់គ្រងបាន។

ដោយឡែកដុល្លារូបនីយកម្មនៅកម្ពុជាគឺជារបបរូបិយវត្ថុ ដែលប្រើប្រាក់ដុល្លារទន្ទឹមនឹងប្រាក់រៀល។ ហើយដុល្លារូបនីយកម្មនៅកម្ពុជាគឺបានកើតឡើងដោយមិនបានគិតទុកជាមុន ក្នុងខណៈដែល អង្គការសហ-ប្រជាជាតិបានបញ្ជូន កងកម្លាំងរក្សាសន្តិភាព និងបុគ្គលិករដ្ឋបាលចូលមកកម្ពុជា នៅក្នុងឆ្នាំ១៩៩៣ ជាមួយនឹងគម្រោងថវិកាសម្រាប់ប្រើប្រាស់ក្នុងប្រតិបត្តិការនេះចំនួនពីរប៊ីលានដុល្លារអាមេរិក។ បុគ្គលិកនិងទាហានទាំងនោះ បានបើកប្រាក់បៀវត្សន៍យកទៅចាយវាយទិញសម្ភារៈ បង់ឈ្នួលផ្ទះនិងសេវាផ្សេងៗជាប្រាក់ដុល្លារអាមេរិកផ្ទាល់ នៅគ្រប់ទិសទីក្នុងប្រទេសកម្ពុជា ចាប់ពីទីក្រុងដល់ជនបទ ចំណែកឯប្រជាជនកម្ពុជាគ្រប់រូបក៏បានស្គាល់ ទទួលយក សន្សំ និងចាយវាយប្រាក់ដុល្លារជាធម្មតារៀងមក ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ក៏ដូចជាក្នុងការប្រកបមុខរបរ។ ទន្ទឹមនេះ វិនិយោគិនបរទេសក៏បានចាប់ផ្តើមចូលមកវិនិយោគនៅកម្ពុជា ដើម្បីបំរើឲ្យប្រតិបត្តិការអង្គការសហប្រជាជាតិ និងប្រទេសមួយចំនួនក៏បានផ្តល់ជំនួយមនុស្សធម៌ និងជំនួយកសាងប្រទេសឡើងវិញ ហើយមូលធនដែលបាននាំចូលមកគឺសុទ្ធសឹងជាប្រាក់ដុល្លារអាមេរិកទាំងអស់ ។

ចាប់ពីពេលនោះមក ប្រាក់រៀលត្រូវបានប្រើប្រាស់សម្រាប់តែចំណាយបន្តិចបន្តួចក្នុងជីវភាពប្រចាំថ្ងៃ ហើយមិនត្រូវបានប្រើជាមធ្យោបាយសន្សំឡើយ រីឯប្រាក់ដុល្លារត្រូវបានប្រើប្រាស់សម្រាប់ទូទាត់ប្រតិបត្តិការសេដ្ឋកិច្ចទាំងខ្នាតតូចនិងធំ ហើយក៏ជាមធ្យោបាយសន្សំផងដែរ។

ដូច្នេះដុល្លារូបនីយកម្មបានកើតឡើងដោយស្ថានភាពតម្រូវ មិនមែនកើតឡើងដោយឆន្ទៈ ឬដោយគោលនយោបាយរបស់រដ្ឋាភិបាលនោះឡើយ។

**៣. ប្រទេសដែលមានសេដ្ឋកិច្ចដុល្លារូបនីយកម្ម**

ប្រទេសកម្ពុជាមិនមែនជាប្រទេសតែមួយគត់ដែលមានសេដ្ឋកិច្ចដុល្លារូបនិយកម្មនោះទេ គឺមានប្រទេសមួយចំនួនទៀត ដែលប្រកាន់យករបបរូបិយវត្ថុដុល្លារូបនីយកម្ម។

ក. ប្រទេសដែលប្រើប្រាស់តែប្រាក់ដុល្លារអាមេរិកជាប្រាក់ជារូបិយបណ្ណរបស់ប្រទេស ជំនួសរូបិយ-បណ្ណរបស់ខ្លួន៖ ប្រទេសទាំងនោះមានទំហំសេដ្ឋកិច្ចខ្នាតតូច ពុំមានលទ្ធភាពដំណើរការធនាគារកណ្ដាលដោយខ្លួនឯង ព្រមទាំងមានអត្រាអតិផរណាខ្ពស់ពេកមិនអាចគ្រប់គ្រងបាន។ ប្រទេសទាំងនោះរួមមាន៖ អេក្វាឌ័រ ទីម័រខាងកើត អែលសាលវាឌ័រ កោះម៉ារសាល មីក្រូនេស៊ា ប៉ាឡូវ ហ្សីមបាបវេ។ល។

ខ. ប្រទេសដែលប្រើប្រាស់ប្រាក់ដុល្លារអាមេរិកទន្ទឹមនឹងប្រាក់រូបិយវត្ថុរបស់ខ្លួនតាមកម្រិតសមាមាត្រតិចឬច្រើន ខុសៗគ្នា៖ កាណាដា រុស្សី ប៉ាណាម៉ា បាហាមាស វៀតណាម កម្ពុជា នីការាហ្គ័រ ។ល។ (យោងតាមឯកសារបរទេស)។

**៤. ប្រវត្តិនៃការប្រើពាក្យដុល្លារូបនីយកម្ម**

គេតែងនិយមប្រើពាក្យដុល្លារូបនីយកម្ម ទោះបីប្រទេសខ្លះប្រើប្រាក់រូបិយផ្សេងក្រៅពីប្រាក់ដុល្លារក៏ដោយ គឺដោយសាររូបិយបណ្ណនេះត្រូវបានប្រើប្រាស់ និងទទួលយកយ៉ាងទូលំទូលាយចាប់តាំងពីសង្គ្រាមលោកលើកទីពីរមក ជំនួសឲ្យប្រាក់ប៉ោនអង់គ្លេសដែលធ្លាក់ថ្លៃដោយសារសេដ្ឋកិច្ចអង់គ្លេសខ្ទេចខ្ទាំដោយសង្គ្រាម។ ប្រាក់ដុល្លារត្រូវបាន ប្រទេសជាច្រើនមានជំនឿទុកចិត្តអំពីស្ថិរភាពយូរអង្វែង និងមិនដែលធ្លាប់ត្រូវបានទម្លាក់តម្លៃម្ដងណាឡើយ ហើយចាប់ពីបញ្ចប់សង្គ្រាមលោកលើកទីពីរមក ការបោះផ្សាយប្រាក់ដុល្លារត្រូវបានធានាដោយមាស។ ក៏ប៉ុន្តែ ទោះបីជាចាប់ពីឆ្នាំ១៩៧០មក ការបោះផ្សាយដុល្លារលែងធានាដោយមាសក៏ដោយ ក៏ជាទូទៅទំនុកចិត្តលើរូបិយបណ្ណនេះនៅតែមាន។

**៥. ផលប៉ះពាល់នៃដុល្លារូបនីយកម្ម**

សម្រាប់ប្រទេសកម្ពុជា ការប្រើប្រាស់ប្រាក់ដុល្លារនៅក្នុងខឿនសេដ្ឋកិច្ចជាតិ បាននាំឲ្យមានផលប៉ះពាល់អវិជ្ជមានផងនិងវិជ្ជមានផង៖

ក. ផលប៉ះពាល់អវិជ្ជមាន

- ប៉ះពាល់ដល់មោទនភាពជាតិ៖ ជាការពិតហើយដែលប្រទេសកម្ពុជាត្រូវតែប្រើប្រាស់ប្រាក់រូបិយវត្ថុជាតិ ការប្រើប្រាស់ប្រាក់ដុល្លារអាមេរិក គឺបានធ្វើឲ្យប៉ះពាល់ដល់មោទនភាពជាតិ។

- ការខាតបង់ចំណូលពី Seigniorage៖

Seigniorage សំដៅដល់ប្រាក់ចំណូលដែលរដ្ឋាភិបាលទទួលបានពីការបោះពុម្ពក្រដាស់ប្រាក់ថ្មី។ ប្រាក់ចំណូលនេះត្រូវបានគណនាដោយយកថ្លៃនៃការបោះពុម្ពក្រដាស់ប្រាក់មួយសន្លឹកដកនឹងតម្លៃចារឹកលើក្រដាសប្រាក់នោះ។ ឧទាហរណ៍ ក្រដាសប្រាក់១០០ដុល្លារ ថ្លៃបោះពុម្ពមួយសន្លឹកអស់ប្រាំសេន ដូច្នេះប្រាក់ចំណូលពី Seigniorage ក្នុងមួយសន្លឹកចំនួន៩៩,៩៥ដុល្លារ។

ខ. ផលប៉ះពាល់វិជ្ជមាន

- ទាក់ទាញវិនិយោគក្នុងស្រុកនិងបរទេស

ក្នុងស្ថានភាពប្រទេសកម្ពុជាដែលក្រោយពីថ្ងៃរំដោះពីរបបខ្មែរក្រហម ជំនឿទុកចិត្តលើប្រាក់រូបិយវត្ថុ

ជាតិនិងលើប្រព័ន្ធធនាគារត្រូវបានបាត់បង់ទាំងស្រុងនោះ ជាសក្ខីកម្មក្នុងរយៈពេលជិត៣០ឆ្នាំកន្លងទៅ បានបង្ហាញថាដុល្លារូនីយកម្មបានចូលរួមចំណែកយ៉ាងធំធេង ក្នុងការទាក់ទាញវិនិយោគិនក្នុងស្រុក និងបរទេសឲ្យហ៊ានបោះទុនវិនិយោគមកកម្ពុជា ដែលជាកត្តាសំខាន់ជំរុញឲ្យមានកំណើនសេដ្ឋកិច្ច។ ជាពិសេសវិនិយោគលើវិស័យធនាគារនិងហិរញ្ញវត្ថុបាននាំមូលធនជាច្រើនចាក់ចូលទៅបំរើឲ្យវិស័យសេដ្ឋកិច្ចតាមរយៈការផ្តល់ឥណទាន។

- រួមចំណែកបង្កើតឲ្យមានជំនឿទុកចិត្តឡើងវិញលើប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុបង្កើតឲ្យមានអន្តរការីយកម្មហិរញ្ញវត្ថុឡើងវិញដើម្បីទាក់ទាញឲ្យមានការសន្សំប្រាក់ ការដាក់ផ្ញើប្រាក់ ការផ្តល់ឥណទាន និងការទូទាត់សងប្រាក់ដោយមិនប្រើសាច់ប្រាក់ឡើងវិញ។

- អាចកាត់បន្ថយផលប៉ះពាល់នៃការប៉ះទង្គិចពីវិបត្តិសេដ្ឋកិច្ចនានាដែលបាន និងអាចកើតឡើង។ ឧទាហរណ៍ វិបត្តិសេដ្ឋកិច្ចអាស៊ីឆ្នាំ១៩៩៧ និងវិបត្តិសេដ្ឋកិច្ចសកលលោកឆ្នាំ២០០៨ បាននាំមកនូវផលប៉ះពាល់តិចតួចដល់សេដ្ឋកិច្ចកម្ពុជា។

**៦. ស្ថានភាពនៃដុល្លារូបនីយកម្មនៅដំណាច់ឆ្នាំ២០១៨**

(ទិន្នន័យដកស្រង់ចេញពី របាយការណ៍ត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជាឆ្នាំ២០១៨)

ស្ថានភាពនៃរូបិយវត្ថុទូទៅនាដំណាច់ឆ្នាំ២០១៨បានឆ្លុះបញ្ចាំងអំពីសូចនាករសំខាន់ៗដូចខាងក្រោម៖

ក. ឥណទានដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានផ្តល់ដល់សេដ្ឋកិច្ចមានចំនួន៖ ១០៣,៨ទ្រីលានរៀលស្មើនឹង ២៦ប៊ីលានដុល្លារ ក្នុងនេះឥណទានជាប្រាក់រៀលមានប្រហែលជាជិត៥ភាគរយ នៃឥណទានសរុបតែប៉ុណ្ណោះ។

ខ. ប្រាក់បញ្ញើអតិថិជននៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានចំនួន ៩៩,៩ទ្រីលានរៀល ស្មើនឹង ២៥ប៊ីលានដុល្លារ ក្នុងនេះប្រាក់បញ្ញើជារៀល មានសមាមាត្រ៦,១% កើនខ្ពស់ជាងឆ្នាំ២០១៧ ដែលមានចំនួន ៥,៩%។

សមាមាត្រដ៏ទាបនៃប្រាក់បញ្ញើនិងឥណទានជារៀល ធៀបនឹងប្រាក់បញ្ញើនិងឥណទានសរុប បានបង្ហាញថាប្រាក់រៀលមិនត្រូវបានប្រើជាមធ្យោបាយសន្សំ ឬជាមធ្យោបាយទូទាត់សងប្រាក់ទំហំធំនោះឡើយ ពោលគឺប្រើសម្រាប់តែការចំណាយតិចតួចប្រចាំថ្ងៃតែប៉ុណ្ណោះ។

**៧. បដិដុល្លារូបនីយកម្ម**

លក្ខណ្ឌបឋមនិងចាំបាច់ដើម្បីគាំទ្រឲ្យការធ្វើបដិដុល្លារូបនីយកម្មទទួលបានជោគជ័យរួមមាន៖

ក. ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចក្នុងរយៈពេលវែង៖

- កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តភាពយូរអង្វែង៖ ក្នុងរយៈពេល១០ឆ្នាំកន្លងទៅកំណើនសេដ្ឋកិច្ចរបស់កម្ពុជា មានកំណើនក្នុងអត្រាមធ្យមប្រ ហែល៧ភាគរយក្នុងមួយឆ្នាំ ដែលជាអត្រាកំណើនដ៏ខ្ពស់ និងមានស្ថិរភាព។

- អត្រាអតិផរណាមានកម្រិតទាប៖ ក្នុងរយៈពេល១០ឆ្នាំកន្លងទៅ អត្រាអតិផរណាស្ថិតនៅក្រោម៥ភាគរយ ជាកម្រិតទាបដែលអាចគ្រប់គ្រងបាន។ រក្សាអត្រាអតិផរណាឲ្យនៅកម្រិតទាប បានន័យថារក្សាបាននូវអំណាចទិញរបស់ប្រាក់រៀលឲ្យនៅថេរដែលជាកត្តារួមចំណែកនាំឲ្យមានទំុកចិត្តលើប្រាក់រៀល ។

- អត្រាប្តូរប្រាក់រៀលធៀបនិងប្រាក់ដុល្លារអាមេរិកមានស្ថិរភាព៖

ប្រទេសកម្ពុជាបានប្រកាន់យករបបគោលនយោបាយប្តូរប្រាក់អណ្តែតដោយមានការគ្រប់គ្រង

(Managed Floating) ចាប់ពីឆ្នាំ១៩៩៨ រហូតបច្ចុប្បន្ន បានន័យថាធនាគារកណ្តាលនឹងធ្វើអន្តរាគមន៍ទិញលក់ប្រាក់រៀល/ដុល្លារនៅលើទីផ្សារ នៅពេលណាដែលអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារមានការប្រែប្រួលហួសពីកម្រិតគោលមួយជាកំណត់។ របបគោលនយោបាយប្តូរប្រាក់នេះ បានធ្វើឲ្យប្រាក់រៀលមានស្ថិរភាព ពោលគឺបម្រែបម្រួលក្នុងឆ្នាំចន្លោះពី៤០០០៛/១ដុល្លារ ទៅ៤១០០៛/១ដុល្លារ ពោលគឺអណ្តែតចុះឡើងក្នុងរង្វង់ពី២ទៅ២,៥ភាគរយក្នុងឆ្នាំ។ ការអណ្តែតចុះឡើងនេះស្ថិតនៅក្រោមឥទ្ធិពល នៃតម្រូវការប្រាក់រៀលតាមរដូវកាល។ គម្លាតនៃការអណ្តែតចុះឡើងប្រាក់រៀលពី២ ទៅ២,៥ភាគរយនេះ ជាអត្រាគម្លាតធំបង្គួរដែលអាចប៉ះពាល់ទំនុកចិត្តមកលើប្រាក់រៀល។ បើសិនជាគម្លាតនេះអាចកាត់បន្ថយមកនៅពី ០,៥ទៅ១ភាគរយទូទាំងឆ្នាំវិញនោះៗសាធារណជននឹងមានទំនុកចិត្តថាប្រាក់រៀលមានស្ថិរភាពជាងមុន និងអាចសន្សំទុកនិងប្រើប្រាស់ប្រាក់រៀល ជាមធ្យោបាយទូទាត់កាន់តែច្រើនឡើង។

ខ. ស្ថិរភាពនិងភាពរឹងមាំនៃវិស័យធនាគារនិងហិញ្ញវត្ថុ

បច្ចុប្បន្ន វិស័យហិញ្ញវត្ថុកម្ពុជាអាចចាត់ទុកថាមានស្ថិរភាពនិងរឹងមាំបង្គួរ ដោយទាក់ទាញបាននូវជំនឿទុកចិត្តពីវិនិយោគិនក្នុងស្រុកនិងបរទេស និងសាធារណជន ឲ្យចូលមកវិនិយោគ និងប្រើប្រាស់សេវាកាន់តែសម្បូណ៌បែបដែលវិស័យនេះកំពុងតែបានផ្តល់ នឹងត្រៀមផ្តល់នៅពេលអនាគត។ ដូច្នេះវិស័យហិរញ្ញ-វត្ថុ គឺជាវិស័យដែលដើរតួនាទីឈានមុខគេក្នុងការជម្រុញបដិដុល្លារូបនីយកម្ម។

២. វិធានការដែលបានអនុវត្តហើយនិងវិធានការជម្រុញលើកទឹកចិត្តការប្រើប្រាស់ប្រាក់រៀល

វិធានការដែលគួរប្រកាន់យកដើម្បីធ្វើបដិដុល្លារូបនីយកម្មគឺ ការបង្កបរិយាកាសឲ្យមានតម្រូវការប្រើប្រាស់ប្រាក់រៀលកាន់តែច្រើនឡើង នៅក្នុងសេដ្ឋកិច្ចជាតិ។

កន្លងមករាជរដ្ឋាភិបាលបានអនុវត្តការលើកកំពស់ការប្រើប្រាស់ប្រាក់រៀលបានមួយចំនួនធំហើយ ដូចជា៖

- កំណត់ការបង់ពន្ធដារគ្រប់ប្រភេទ លទ្ធកម្ម បើកប្រាក់បៀវត្សន៍មន្ត្រីរាជការទូទាត់សេវាកម្មមួយចំនួនរបស់រដ្ឋ និងការបង់ថ្លៃទឹកនឹងអគ្គិសនីជាប្រាក់រៀល។ បើសិនជារាជរដ្ឋាភិបាលពង្វាតការប្រើប្រាស់ប្រាក់រៀលឲ្យមានវិសាលភាពគ្របដណ្តប់លើគ្រប់សេវាកម្មរបស់រដ្ឋទាំងអស់នោះ សមាមាត្រនៃប្រាក់រៀលនៅក្នុងខឿនសេដ្ឋកិច្ចនឹងកើនឡើង យ៉ាងច្រើនបន្ថែមទៀត។
- តម្រូវឲ្យវិស័យឯកជនដាក់ថ្លៃទំនិញនិងសេវាលក់រាយមួយចំនួនជាប្រាក់រៀល។ ប៉ុន្តែការកំណត់នេះ មិនទាន់គ្របដណ្តប់ទូទាំងវិស័យឯកជននៅឡើយ នៅមានផ្នែកខ្លះ ថ្លៃទំនិញនិងសេវាកម្មនៅតែដាក់ជាប្រាក់ដុល្លារនៅឡើយ ហើយអ្នកលក់ខ្លះដោយមិនចង់ទទួលយកប្រាក់រៀល ក៏យកបញ្ហាអត្រាប្តូរមិនសមស្របមករាំងស្ទះ នាំឲ្យអតិថិជនងាកទៅប្រើដុល្លារវិញព្រោះប្រើប្រាក់រៀលខាតជាងប្រើដុល្លារ។ ដូច្នេះការដាក់បញ្ញត្តិក្នុងការប្រើប្រាស់អត្រាប្តូរ ឬក៏តម្រូវឲ្យទទួលយកតែប្រាក់រៀលចំពោះសេវាកម្ម និងទំនិញលក់រាយជាកត្តាសំខាន់ ដែលរួមចំណែកឲ្យការប្រើប្រាស់រៀលកើនឡើង។
- បង្កើតឲ្យមានទីផ្សារមូលបត្រ ដោយលើកទឹកចិត្តឲ្យសហគ្រាសរដ្ឋនិងឯកជនបោះផ្សាយមូលបត្របំណុលជាប្រាក់រៀល ដើម្បីកៃនប្រមូលទុនជារៀលយកទៅប្រើប្រាស់ក្នុងអាជីវកម្ម។

• កំណត់ឲ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុផ្តល់ឥណទានឲ្យបាន ១០ភាគរយនៃឥណទានសរុបត្រឹមដំណាច់ឆ្នាំ២០១៩។

• លើកទឹកចិត្ត និងបង្កលក្ខណៈងាយស្រួលបង្កើតឲ្យមានប្រព័ន្ធទូទាត់សងប្រាក់រៀលឆាប់រហ័សដោយមិនប្រើក្រដាស់ប្រាក់ នៅក្នុងប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ចៀសវាងការដឹកជញ្ជូន ការរាប់ក្រដាសប្រាក់ដែលនាំឲ្យខាតពេលវេលា គ្មានសុវត្ថិភាពនិងចំណាយពេលច្រើន។

### ៨. សន្និដ្ឋាន

ដុល្លារូបនីយកម្មនៅកម្ពុជាគឺបានចាក់គ្រឹះរឹងមាំជាយូរ រយៈពេល៣០ឆ្នាំហើយ ដូច្នេះការផ្លាស់ប្តូរទៅជាការប្រើប្រាស់ប្រាក់រៀល តម្រូវឲ្យមានការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធទាំងអស់ រួមមានរាជរដ្ឋាភិបាល ប្រជាជននិងប្រតិបត្តិករសេដ្ឋកិច្ចរដ្ឋនិងឯកជន។

រហូតដល់បច្ចុប្បន្ន រាជរដ្ឋាភិបាលបានសម្រេចបាននូវលក្ខណ្ឌចម្បងៗ ដែលគាំទ្រឲ្យមានការលើកទឹកចិត្តការប្រើប្រាស់ប្រាក់រៀល និងបានចាត់វិធានការមួយចំនួនរួចហើយ អ្វីដែលគួរធ្វើជាបន្តទៀតគឺការជម្រុញបន្ថែមនិងការដាក់ផែនការសកម្មភាពច្បាស់លាស់ រយៈពេលកំណត់មួយ ដើម្បីកាត់បន្ថយជាបណ្តើរៗនូវប្រាក់ដុល្លារពីសេដ្ឋកិច្ចជាតិ។ ការកាត់បន្ថយការប្រើប្រាក់ដុល្លារ គួរចាប់ផ្តើមពីសកម្មភាពដែលពាក់ព័ន្ធនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន ដោយចាត់វិធានការធ្វើឲ្យអ្នកមានជីវភាពកម្រិតមធ្យមចុះក្រោមមានចំណូលជារៀលនិងចំណាយទៅវិញជារៀលដើម្បីចៀសវាងការខាតបង់ពីការប្តូរប្រាក់។

និយាយរួម វិធានការរដ្ឋបាលចាប់បង្ខំ មិនមែនជាវិធានការដែលគួរយកមកអនុវត្តឡើយ ព្រោះថាផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរនឹងអាចកើតឡើងមិនអចប៉ាន់ស្មានបាន នាំឲ្យរាំងស្ទះដល់ដំណើរការសេដ្ឋកិច្ចបច្ចុប្បន្នដែលកំពុងអភិវឌ្ឍដ៏រលូននិងមានចិរភាព៕

---

*រៀបរៀងដោយលោកជំទាវ គាល់ ណៃអ៊ីម ទីប្រឹក្សាបច្ចេកទេស ក.ស.វ*

<u>**គំនិតគួរចងចាំ**</u>

" អ្នកបួសធ្ងន់ក្នុងលាភយសមិនបវរ គ្រហស្ថគ្មានមុខរបរមិនថ្លៃថ្នូរ។ "

សម្តេចព្រះធម្មលិខិត **ល្វី ឯម ខេមរិន្ទញ្ញោ**



រូបភាពក្នុងកិច្ចប្រជុំវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌